ចិត្រាដឹងថា បុរសនេះក៏កំពុងតែមានពិភាល់មិនស្រួលក្នុងចិត្តប៉ុន្មានដែរ ម្ល៉ោះហើយមិនបង្អង់យូរឡើយ នាយនិយាយបន្ថែម៖

«ល្ងាចមិញពេលអ្នកនាងប្រើយកថ្នាំ ខ្ញុំចាប់អារម្មណ៍ថាបានឃើញPoster មួយស្រដៀងនេះនៅក្នុងឡានគាត់!»

កូនស្រីនៅសុខៗកុម្ម៉ង់អាវចូលរួមកម្មវិធីដ៏មានតម្លៃ ហើយថែមទាំងពេលនេះនាងមាន Posterកម្មវិធីចម្លែកនៅក្នុងរថយន្តទៀត មិនឲ្យលោកឧត្តមសេនីយ៍ចាប់អារម្មណ៍ទើបចម្លែក។

គាត់ទាញក្រដាសមកមើល ហើយមាត់សួរបញ្ជាក់សារចុះឡើង៖

«posterនេះពិតជាទាក់ទង ជាមួយអ្នកបាត់ខ្លួនមុនៗ?»

អស់ពេលលាក់លៀមបាន វរសេនីយ៍ត្រីសារភាព៖

«តាមពិតទៅឯកមានមិត្តរបស់ខ្ញុំជាអ្នកលេងកូដដ៏ពូកែ! គេងឿងឆ្ងល់លើក្តីនេះហើយគេក៏ស្រាវជ្រាវលេងៗ ទីបំផុតគេរកឃើញពន្លឺអស់ទាំងនេះ! ពិធីសមោសរពណ៌ព្រះចន្ទជាពិធីសម្ងាត់សម្រាប់ពួកយុវវ័យអភិជនដែលអាចជួបមនុស្សល្បីៗ ក្នុងសង្គមពួកគេ! ខ្ញុំដឹងថាមនុស្សម្នាក់គួរឲ្យសង្ស័យជាងគេក្នុងសំណុំរឿងនេះ!»

«អ្នកណាគេ?»

ឧត្តមសេនីយ៍សួរយ៉ាងម៉ឺងម៉ាត់។

សក្តិប្អូនដឹងថាមេកោយ កំពុងយល់ស្របជាមួយពន្លឺចុងក្រោយដែលអាចថាជាយាន ឈានទៅបំបែករឿងក្តីដ៏រំជើបរំជួលមួយនេះបាន។ អ៊ីចឹងហើយគ្មានហេតុផលអ្វី ដែលខ្លួនត្រូវលាក់លៀមជាមួយគាត់ទៀតឡើយ។ នាយឆ្លើយរូ៖

«ជាបឋមយើងអាចដាក់ការសង្ស័យ អ្នករៀបចំកម្មវិធីនេះជាមនុស្សប្រុសអ្នកមានកប់ក្តោងម្នាក់ ឈ្មោះ មហាវីន!»

បុរសចំណាស់សម្លឹងមុខនាយ ភ្លឹះៗ ហើយងាកទៅទាញទូរសព្ទមកចុច។ ចិត្រានៅបង្អង់រង់ចាំមើលប្រតិកម្មគាត់។ នាយឃើញគាត់បញ្ជាស្ងាត់ៗ៖

«បងហឿន! ផែកឡានអ្នកនាងរកផៀបការ ផៀបកម្មវិធី ក្រដាសអ្វីក៏ដោយ ឃើញហើយប្រមូលទាំងអស់យកមកឲ្យខ្ញុំ! »

គាត់សម្លឹមុខចិត្រាមុនពេលនិយាយបន្តដាក់មនុស្សចំណាស់ដែលយាមផ្ទះនៅខាងក្រោម៖

«មួយទៀត! ហាមនិយាយរឿងនេះប្រាប់កូនដាដាច់ខាត ធ្វើឲ្យស្ងាត់!»

គាត់ដាក់ទូរសព្ទ ចុះហើយងាកមកសម្លឹងមុខចិត្រា។

យុវជនវ័យក្មេងនេះ នៅនឹងមុខកូនស្រីគាត់ជាអង្គរក្សឱនលំទោន ចុះហេតុអ្វីពេលនិយាយអំពីរឿងក្តី គេមានបុគ្គលិកលក្ខណៈច្បាស់លាស់និងភ្លឺស្វាងគួរឲ្យស្ងើចសរសើរម្ល៉េះ?

«ខ្ញុំជ្រើសរើសលោក ចូលរួមជាមួយការងារនេះ មិនខុសមែន វរសេនីយ៍ត្រីជាតិ ចិត្រា!»

ការដែលមេកោយប្តូរពី «ឯង» មកជា «លោក» ប៉ូលិសក្មេងយើងមិនអំនួត បែរជាកើតរអៀសខ្លួននឹងពាក្យសរសើរម្តងហើយម្តងទៀតនេះ។ គេចាំបាច់ត្រូវតែសារភាពបន្ទូរចិត្តខ្លួនឯង៖

«មិត្តខ្ញុំទេទាន! គេពាក់សក្តិប្អូន ឈ្មោះឯកមាន នៅអង្គភាពប្រឆាំងបទល្មើស បច្ចេកវិទ្យា! គេទេដែលមានគុណសម្បត្តិធំក្នុងរឿងនេះ!»

ឧត្តមសេនីយ៍ញញឹមឈ្ងោកមើលឥដ្ឋ ទំនងជារកពាក្យមកនិយាយឲ្យសម។ ទោះបីជាយ៉ាងណាជាតិ ចិត្រាមើលដឹងថា បុរសនេះកាន់តែទទួលស្គាល់ក្រុមខ្លួនកាលណា អាកប្បកិរិយាគាត់រឹងរឹតតែគួរសមជាងមុន គួរឲ្យកត់សម្គាល់។

ពេលនាយនៅស្ងៀម ឧត្តមសេនីយ៍ ឱត សាម៉ុន លៀនអណ្តាតរិះគិត មុនពេលដាច់ចិត្តហានិយាយមួយៗមករកគូសន្ទនា៖

«ពេលដំបូង ខ្ញុំស្មានថាឧត្តមសេនីយ៍សេត វិទូ ជួយរកតម្រុយនេះឲ្យលោក!»

វរសេនីយ៍បដិសេធបន្ទាន់៖

«ពូខ្ញុំឈប់ហើយ! គាត់ឈប់ទាំងស្រុង! ខ្ញុំមិនដែលយករឿងបែបនេះទៅនាំអំពល់គាត់ទេទាន!»

កែវភ្នែក ឧត្តមសេនីយ៍ ហាក់រំភើបពេលរំឭកទៅដល់ឈ្មោះបុរសសេតវិទូ ទោះបីចម្លើយក្តួយប្រុសគេ កំពុងបកមកវិញមិនមានវិជ្ជមានក៏ដោយ។

គាត់នៅស្ងៀម ហើយលាក់ការគិតជាច្រើននៅក្នុងអាកប្បកិរិយាស្ងួតស្ងប់ ខុសពីខាងលោកសក្តិប្អូនយើងដែលនៅមិនស្ងប់ត្រូវតែសួរ៖

«លោកនាយអនុញ្ញាតឲ្យខ្ញុំចូលរួមការងារដ៏សំខាន់នេះ ព្រោះតែយល់មុខលោកមា?»

សំណួរទោមនស្សជាប្រយោលរបស់អ្នកកំលោះ ហាក់ទាញគាត់ឲ្យភ្ញាក់ខ្លួនមកវិញ ហើយកែប្រែឥរិយាបថ។ គាត់ទើបនឹងចាប់អារម្មណ៍យល់ថា បុរសក្មេងនេះ ក្រៅពីគោរពឋានានុក្រមខ្ជាប់ខ្ជួននិងគោរពភារកិច្ចចាត់តាំងនានាមិនដែលហ៊ានតវ៉ា គេពុំមែនជាបុគ្គលដែលគ្មានគំនិតផ្ទាល់ខ្លួននោះទេ។

ជំនួសឲ្យចម្លើយ គាត់លូកបាតដៃស្តាំមកទះស្មានាយ ហើយនិយាយស្រស់ស្រាយ៖

«ឈប់មើលស្រាលខ្លួនឯងដោយការស្មានទាំងអស់ហ្នឹងទៅ!»

គេធូរចិត្ត ដែលដឹងថាខ្លួនឯងស្មានខុស។

ពូហឿន ខលត្រឡប់មកវិញ ធ្វើឲ្យឧត្តមសេនីយ៍ផ្អាកសន្ទនាហើយចុចស្តាប់។ គាត់នៅស្ងាត់ស្ងៀមស្តាប់សេចក្តីរាយការណ៍ ទុកឲ្យចិត្រាតាមសម្លឹងអាកប្បកិរិយាគត់មត់នៃបុរសនេះ។

អ្វីដែលនាយគិតក្នុងចិត្តភ្លាមមក គ្មានអ្វីក្រៅអំពីថាពេលណាទើបខ្លួនឯងមានចរិតពេញប្រៀបជាមនុស្សប្រុសម៉ឺងម៉ាត់ គត់មត់ នឹងន  ហើយលែងវិភាគអ្វីៗដោយការកាត់ស្មានទៀត?

«ពូហឿនថា គាត់គ្មានរកឃើញអីទាំងអស់! ធៀបមួយក៏គ្មានដែរក្នុងឡានកូនដា!?»

ចិត្រាភ្ញាក់ផ្អើល...។

ពេលលោកឧត្តមសេនីយ៍ឈ្ងោកបិទប៊ូតុងទូរសព្ទ កាយវិការ គាត់យឺតៗហាក់ដូចកំពុងពិចារណារឿងសំខាន់អ្វីមួយ ដូច្នេះវរសេនីយ៍ត្រីឆ្លៀតនិយាយភ្លាម៖

«ខ្ញុំឃើញច្បាស់ណាស់ទានគឺ...»

«ខ្ញុំជឿលោក!»

គាត់និយាយកាត់ខ្លី ហើយងើបមុខមកវិញ។ បុរសចំណាស់ចោលក្រសែភ្នែកបង្កប់នូវដំណោះស្រាយនិងគំនិតវាងវៃជាច្រើន ធ្វើឲ្យនាយសក្តិបួនយើងបាត់មាត់ហើយរង់ចាំស្តាប់គាត់។

ពិតណាស់ គាត់ងក់ក្បាលហើយនិយាយបន្តៈ

«បើសិនអ្វីដែលលោកឃើញហើយចាំបាន នោះមិនមែនជាការព្រិលភ្នែកភ័ន្តច្រឡំ កូនខ្ញុំប្រហែលកំពុងលេងបួនសន្លឹកដាក់ឪពុក!»

ត្បិតតែនារីនេះមិនដែលបង្កើតនូវសកម្មភាពល្អណាមួយឲ្យខ្លួន ប៉ុន្តែនាងពិតជានារីស្មោះត្រង់ម្នាក់តាមក្រសែភ្នែកនាយជាអង្គរក្ស។ ឲ្យនាងនិងឪពុកមានការខ្វែងគំនិតគ្នាពិតជាពុំមែនបំណងពិតរបស់ ជាតិ ចិត្រាឡើយ។ គេប្រឹងប្រែងពន្យល់ឧត្តមសេនីយ៍ៈ

«ខ្ញុំមិនចង់ឲ្យលោកនាយ យល់ខុសលើអ្នកនាងទេ! ខ្ញុំថាបើយើងកំណត់មុខសញ្ញាបានហើយ ម្នាក់ឈ្មោះមហាវីននោះ បានសមជាគោលដៅ!»

ឱិត សាម៉ុន សើចតិចៗ។ នាយរង់ចាំស្តាប់សម្តីនៅពីក្រោយស្នូរសំណើចរបស់គាត់។ ទីបំផុតនាយវាចាតិចៗៈ

«ខ្ញុំល្ងង់ណាស់ទាន! ហើយជាមនុស្សអន្ទះសា!»

បុរសចំណាស់ អោបស្មានាយដោយប្រើដៃម្ខាង ហើយនិយាយលួងៈ

«កាលពូនៅក្មេងក៏មិនខុសពីលោកដែរ វរសេនីយ៍ត្រី!»

គេងក់ក្បាលលំឱនកាយហាក់ដឹងកំហុសទាំងខ្លួនកំពុងនៅក្នុងរង្វង់ដៃពោរពេញទៅដោយភាពជិតដិតជាមួយថ្នាក់លើ។ ឧត្តមសេនីយ៍ ឱិត សាម៉ុន និយាយបន្ថែមតិចៗខ្សឹបៗៈ

«មិនបាច់ទៅរកឯណាឆ្ងាយ! ខ្ញុំឲ្យកូនខ្ញុំទៅតែម្តង! បន្លាយខ្សែឲ្យវែងក្រែងសត្វងាយជាប់!»

ចិត្រាប្រហោងពោះ។ សំណួរមុនគេក្នុងពេលនេះគឺ បុរសនេះដើម្បីបំបែកសំណុំរឿង សុខចិត្តទម្លាក់នុយសំណព្វមួយនេះទៅបញ្ចូលក្នុងមាត់ខ្លា?

នឹកឃើញដល់ស្រីស្អាតម្នាក់នោះ និងសម្តីគួរឲ្យស្រលាញ់របស់នាង «មកអង្គុយលើក្បាលខ្ញុំម៉ងក៏បាន!»... ចិត្តវរសេនីយ៍ត្រីចាប់ផ្តើមរង្គោះរង្គើ ហើយទឹកមាត់ចាប់ផ្តើមសាប។ «គ្រោះថ្នាក់ពេកហើយទាន!»

គេនិយាយទាំងភ័យផ្អែមមាត់។ ពេលនេះលែងគិតថា ភាពភ័យខ្លាចរបស់ខ្លួនអាចនឹងត្រូវបុរសនេះចាប់ថ្នាក់បានថាជាយុវវ័យមិនរឹងមាំ គ្មានបានការអ្វីទៀតហើយ។ គេគិតតែម្យ៉ាងថា ប្រសិនបើនារីនេះ នឹងបាត់ខ្លួនទៅតាមលំនាំ អ្នកមុនៗទៀតមែន តើខ្លួនទទួលខុសត្រូវចំពោះគ្រោះថ្នាក់នេះបានដែរទេ ឬត្រូវស្ពាយវិប្បដិសារីត្រឡប់ទៅផ្ទះ។

ទោះយ៉ាងណាលោក ឱត សាម៉ុន ក្តោបស្មានាយកាន់តែណែន ហើយនិយាយ៖

«លោកគិតថា ខ្ញុំឲ្យវាធ្វើអីកូនស្រីតែមួយគត់របស់ខ្ញុំ?»

គេនៅទ្រឹង មិនដឹងឆ្លើយអ្វីព្រោះបុរសនេះ មិនត្រឹមតែមានឋានៈជាមេកោយ ដែលចាំបាច់ត្រូវធ្វើតាម គាត់ថែមទាំងមានសមត្ថភាពអានដឹងចិត្ត គំនិត គ្រប់យ៉ាងដែលនាយកំពុងគិតផង?

«តោះ! ខ្ញុំត្រូវការជួបមិត្តរបស់លោក! ស័ក្តិបួនម្នាក់ទៀតនោះ!?»

ឧត្តមសេនីយ៍តឿនបន្ថែម។

អ៊ីចឹងហើយ ស្នេកឡើង អង្គរក្សទៅតាមអ្នកនាងដល់ទៅពីរនាក់។

...ខុសពីខាងឪពុកដែលកំពុងអន្ទះសារឿងដាក់នុយស្ទូចត្រីយក្ស ខាងស្រីៗទាំងពីរកំពុងភ្លើតភ្លើនក្នុងការចូលរួមពិធីជប់លៀងសម្ងាត់របស់ពួកយុវវ័យសង្គមជាន់ខ្ពស់។

សូម្បីនៅសាលារៀនពេលនេះ ផានូនិង អមរាជា គ្មានគិតអ្វីក្រៅតែពីរឿងសប្បាយរំភើបចំពោះកម្មវិធី «រាត្រីសមោសរពណ៌ព្រះចន្ទ» ដែលនឹងកៀកចូលមកដល់។

«អាវរ៉ូបគ្នា ល្មមម៉ាច់ផានូ! លហើយគ្នាសប្បាយចិត្តដល់ហើយ រាប់ថ្ងៃឲ្យតែកម្មវិធីដល់!»

អមរាជាញញឹមចិញ្ចាច ធ្វើឲ្យផានូដឹងភ្លាមថាអ្នកណាទៅដែលអាចធ្វើឲ្យកូនស្រីឧត្តមសេនីយ៍សប្បាយដល់ថ្នាក់នេះ? បើមិនប្រុសអ្នកមានលាក់មុខ Lorenzoតើជាអ្នកណាវិញ?

ផានូសម្លក់ភ្នាញ់ហើយ បង្អាប់៖

«កុំអាលសប្បាយ រកវិធីដោះស្រាយរឿងមួយនោះឲ្យហើយសិនទៅ!»

នាងបូញមាត់ទៅខាងស្តាំដៃ ធ្វើឲ្យអមរាជាឆ្អែតចិត្ត នឹកឃើញភ្លាមដល់នាយអង្គរក្សដែលឈរសំកាំងយាមដូចបក្សីរង់ចាំក្រុងក្បែរៗខ្លួន រកតែធ្វើអ្វីមួយក៏មិនអាចមានសេរីភាពពេញលេញបាន។

«ខូចអារម្មណ៍!»

អមរាជារអ៊ូទាំងសៅហ្មង ហើយធ្វើមុខស្មើវិញមួយរំពេច។ ចំណែកផានូវិញនិយាយបន្តទាំងញាក់ភ្នែក៖

«មិនត្រឹមតែម្នាក់ទេនាង ឯងមើលទៅក្រោមដើមឈើនោះផង!»

អមរាជាភ្ញាក់សឹងផ្ងារពីបង់អង្គុយរបស់សាលា ព្រោះព្រឹកនេះមិនត្រឹមតែនាយស័ក្តិបួនចិត្រាម្នាក់ដែលជាឆ្អឹង កំពុងជាប់កដោះមិនចេញ ពេលនេះលេចវត្តមាននាយឯកមានមកក្រពាត់ដៃយាមម្ខាងម្នាក់ទៀត។

ធីតាអភិជនធ្វើមុខឡិងឡង់ ហើយងាកសួរបញ្ជាក់មិត្ត៖

«កុំប្រាប់ថាថ្ងៃនេះលោកប៉ាបន្ថែមអង្គរក្សឲ្យយើងណ៎ា!?»

ផានូញញឹមញាក់ចិញ្ចើម៖

«មួយសាលានេះមានកូនស្រីមេប៉ូលិសប៉ុន្មាននាក់? បើអាប៉ិម្នាក់ទៀតហ្នឹងមិនមែនប៉ាឯងគាត់ចាត់មក តើគេវែកដីចូលមកបរិវេណហ្នឹងបានតាមរបៀបណា? បើមិនមែនប៉ាឯងស្និទ្ធនឹងនាយកសាលា ស្មានថាអង្គរក្សពីរនាក់ហ្នឹងចេញចូលបានស្រេចចិត្ត?»

ភាពស្រស់បំព្រងរលត់បាត់ អមរាជាចងចិញ្ចើមក្រញូវ។ នាងក្រោកឈរប្តូរកន្លែងអង្គុយទៅបង់ថ្មមួយផ្សេងឆ្ងាយពីចិត្រា ស្រាប់តែគេឈានទៅតាមក្បែរៗដដែល។

នារីនេះតាំងចិត្តមិននិយាយរកអង្គរក្ស ហើយអូសដៃមិត្តដូរកន្លែងទៀត ចិត្រាឈានទៅតាមទៀត នាងរាដៃឃាត់ទាំងមុខក្រញូវ ហើយនិយាយហាម៖

«បងឯងឈប់មកតាមខ្ញុំ! ចង់យាមអី យាមឲ្យឆ្អែតទៅ តែអាណិតនៅឲ្យឆ្ងាយៗពីខ្ញុំ កាន់តែឆ្ងាយកាន់តែល្អ!»

ចិត្រាហាមាត់និយាយតប៖

«ភារៈជាអង្គរក្ស ចៅហ្វាយនៅត្រង់ណា ត្រូវនៅត្រង់ណោះ! ពេលឈរការពារ មិនឲ្យឈរពីមុខ មិនឲ្យនៅពីក្រោយ មិនឲ្យ…………!»

«បងឯងឈប់សូត្រកំណាព្យអត់គ្រប់ទឹកនឹងភ្លាមឮនៅ?»

គេអាក់មាត់ឈឹង ធ្វើឲ្យផានូ ក្រពាត់ដៃ ទប់សំណើចមិនចង់ជាប់ ដែលមិត្តធ្លាប់តែទន់ភ្លន់ ប្រែមកជាកាចជាងកប៉ាល់ភ្លើង។ ងាកទៅខាងណោះ ឯកមានសម្លឹងមុខ ចិត្រាដូចចង់ឌឺថា «អ្នកនាងឯងសុភាពមែនអាម៉ាក!»។

អមរាជាមិននិយាយអ្វីទៀត ព្រោះចង់បង្ហាញថានាងកំពុងខឹងពេញបន្ទុក។ ស្រីស្អាតទាញកាតាបដើរធ្ងន់ទៅអង្គុយបង់មួយទៀតនៅចុង។ ចិត្រាបម្រុងឈានតាមទៀត ផានូឱនមកខ្សឹបប្រាប់៖

«បងឯងពូកែតាមប្រយ័ត្នស្តាយក្រោយណ៎ា!»

ចិត្រានៅស្ងៀម មើលមុខផានូភ្លឹះៗធ្វើឲ្យនារីអភិជនបានឱកាសបំភ្លៃនាយ រកវិធីនិយាយបន្ថែមមិនចេះទ័លៈ

«អមរាជា ពេលខឹង គឺចម្លួតចូលពេញខ្លួនហ្មង បងឯងមិនដឹងទេ កាលថ្នាក់ទីបួន គេធ្លាប់ខឹងគ្រូ ហើយក្រោកទៅឈរលើមាត់បង្អួចប្រុងលោតចុះមកពីជាន់ទីពីរ!»

«ជាន់ទីពីរ?»

អង្គរក្សចូលស៊ងនារីពូកែកុហកនេះដោយមិនដឹងខ្លួន ហើយចាប់ផ្តើមផ្អែមមាត់។ បានដូចចិត្តផានូនិយាយបន្ថែមខ្សឹបៗ៖

«បងឯងនៅចម្ងាយហ្នឹងហើយ! ចាំរឿងអមរាជា ខ្ញុំចាត់ការការពារឲ្យ! មានអីមិនស្រួលខ្ញុំប្រាប់បងឯង! ខ្ញុំហៅចាំចូលមក! ខ្ញុំទៅលួងគេសិន! គេអារម្មណ៍មិនទាន់ស្រួលរឿងប្រលងភ្លេងធ្លាក់!»

ផានូ ចេញមកទាំងលួចញញឹមខ្ទឹប ព្រោះដឹងថាអង្គរក្សលែងហ៊ានតាមមក។

នៅឯណោះបានមិត្តមកក្បែរភ្លាម គ្មានវត្តមានអង្គរក្សនៅជិតនាងរអ៊ូបន្ទាន់៖

«អ្នកហែហមតែម្នាក់ហ្នឹង ចង់ថប់ដង្ហើមម្តងៗហើយ ថែមម្នាក់មកទៀតប៉ាអើយប៉ា???»

នឹកឃើញដល់រឿងអ្វីសំខាន់ នាងងាកមករកផានូហើយសួរនាំរឹង៖

«នែ៎! យើងសង្ស័យដល់ហើយ! ដែលម្សិលមិញឯងប្រើគេនោះឲ្យទៅឆែកឡានយើង គេឃើញសំបុត្រនោះដឹង? បានជាប៉ាបន្ថែមមនុស្ស?»

ផានូស្លេកមុខ ហើយនៅស្ងៀមពិចារណាទាំងដៀងភ្នែកពិនិត្យអ្នកយាមកាមទាំងពីរមិនហ៊ានប្រហែស។ ភាពស្ងាត់ស្ងៀមរំលងទៅបានបន្តិច ផានូរមិលមកជិតមិត្តហើយខ្សឹប៖

«ប្រហែលអត់ទេ! សង្ឃឹមថាប៉ុហ្នឹងមិនចាប់អារម្មណ៍ចុះ! កម្មវិធីហ្នឹងគេតឹងណាស់! បើគេដឹងយើងមានអ្នកតាម ដល់ថ្ងៃនោះគេមិនឲ្យយើងដឹងកន្លែងទេ!»

អមរាដា ប្រឹងលួងចិត្តខ្លួនឯង និងសម្រួលទឹកមុខសង្ស័យរបស់ខ្លួនចេញតាមរយៈវាចាខែងរ៉ែង៖

«មែនហ្នឹង! មនុស្សមើលទៅស្ទក់ ដូចប៉ុហ្នឹងមកចាប់អារម្មណ៍ហ្អីដែលមកចាប់អារម្មណ៍Posterរបស់យើង! ណាមួយគ្នាយកចេញបាត់ហើយ! គ្មានដានទុកឲ្យប៉ុហ្នឹងទេ!»

នឹកឃើញរឿងមួយទៀត នាងចាប់ផ្តើមមួហ្មងជាថ្មីហើយងាកសួរមិត្ត៖

«អឺ! ហើយចុះ??? ដល់ពេលហ្នឹងទៅម៉េចកើត បើនៅចងកម្មពៀរតាមមុខក្រោយអ៊ីចឹង???»

ផានូ រិះគិតចុះឡើង ហើយលើកទូរសព្ទមកបើកសំយុង កាមេរ៉ាលបលួចមើលសកម្មភាពអង្គរក្សទាំងពីរពីចម្ងាយ មុនពេលឆ្លើយទាំងក្តាប់មាត់៖

«មានគ្នាហើយ ឯងកុំភ័យឲ្យសោះ! យើងមានវិធីអាចបណ្តេញប៉ុហ្នឹងចេញពីជីវិតឯងក្នុងថ្ងៃរាត្រីសមោសរពណ៌ព្រះចន្ទរបស់យើងបាន!»

អមរាឧទានទាំងមួម៉ៅ៖

«និយាយមក! កុំនៅវែងឆ្ងាយ!»

«យើងជម្រាបអ៊ំប្រុសថាតែកុងយើងនឹងមកទទួលឯងទៅជាមួយយើង!»

អមរាដាពេបមាត់៖

«ល្បិចខ្សោយៗ! ប៉ាម៉ាកយើងគ្មានថ្ងៃព្រមទេ!»

ផានូ ក្រញូវពេលត្រូវមិត្តបង្អាប់។ នារីអភិជនសួរបកវិញផូង៖

«បើល្បិចយើងខ្សោយពេក បញ្ចេញល្បិចខ្លាំងៗរបស់ឯងមកនាង!»

អមរាដាបានចិត្តដែលកាច់បំបាក់មិត្តបាន រួមជាមួយការនឹកឃើញដល់អ្វីមួយគួរឲ្យសប្បាយចិត្តផង នាងញាក់ចិញ្ចើមតបទាំងសើចស្រស់៖

«យើងនឹងទាក់ទងបង ឈុនរាជ!»

ផានូងាកមកឃ្មាំង...

«បង ឈុនរាជ???»

ឈុនរាជ បងធំល្បីឈ្មោះប្រចាំសាលា។ អ្នកណាៗរៀននៅមហាវិទ្យាល័យនេះរមែងតែងស្គាល់ឈ្មោះនិងធ្លាប់ឮពីសេវាកម្មការពារ និងធ្វើខ្នងបង្អែកប្រកបដោយសុវត្ថិភាព ប្រសិនបើអ្នកណាម្នាក់មានលុយទៅរកពឹងពាក់។

ឈ្មោះបុគ្គលនេះបានធ្វើឲ្យផានូ ភ័យរអើល ងាកមកសម្លឹងមិត្តភ្លឹះៗសួរបញ្ជាក់៖

«យើងពិតជាទ័លដល់ថ្នាក់រកបងធំមកជួយ!»

អមរាដាយកកែងដៃកេះមិត្តឲ្យឈប់ភ្លាមហើយ រេមើលអង្គរក្សទាំងពីរតាមកន្ទុយភ្នែក ទាំងមាត់បន្ទោស៖

«កុំនិយាយផ្តាសមើល! បងធំអី? គាត់រៀមច្បងសោះហ្នឹង! រៀមច្បងហៅឲ្យស្រួលមើល!»

ផានូសម្លក់នាងហើយរអ៊ូរង៉ូវ៖

«ពាក្យឲ្យល្អស្តាប់ ពាក្យផ្លូវការឲ្យតែល្អមើលហ្នឹង!»

វគ្គ  រៀមច្បងកាងសាលា

«ស្អីគេអមរាដា! ក្រែងថានាំយើងទៅជួបបង ឈុនរាជ ហើយមកក្នុងបន្ទប់ទឹកធ្វើអី?»

ផានូ សួរទាំងងឿងឆ្ងល់ព្រោះត្រូវកូនស្រីឧត្តមសេនីយ៍ដឹកដៃមករកបន្ទប់ទឹកលឿនស្លេវ។ ជុំវិញទីនេះគ្មានអ្នកណាទេ ម្ល៉ោះហើយអមរាដាខ្សឹបប្រាប់៖

«បើមិនចូលមកក្នុងបន្ទប់ទឹក ស្មានថាគេចប់ប៉ូលិសពីរនាក់រនុកក្នុងផុនប៉ាយើងហ្នឹងរួចដែរ?»

ផានូឆ្លេឆ្លាមើលឆ្វេងស្តាំ ហើយខ្សឹបសួរវិញ៖

«ហើយឯងប្រាកដអត់ថា ប៉ុពីរនាក់ហ្នឹង អត់ចូលមកតាមយើង?»

«គេមិនមែនធ្វើអង្គរក្សទាល់តែឡប់មកចូលបន្ទប់ទឹកស្រីៗការពារយើងទេ! បើមែនយើងឆ្កួតតាមតែម្តង! គ្រាន់តែនិយាយ ក៏ចង់កើតមួម៉ៅឡើងវិញដែរ ពេលនឹកដល់ប៉ុអ្នកយាមមនុស្សយន្តហ្នឹង!»

ផានូនៅតែទាញជាយអាវមិត្ត ហើយសួរមិនចប់៖

«អឺ! បើនេះជាបន្ទប់ទឹកស្រី បងឈុនរាជ ចូលមកជួបពិគ្រោះ ជាមួយឯងម៉េចបាន?»

អមរាជាជ្រួញចិញ្ចើមបន្ទោស៖

«មិនចេះខលនិយាយគ្នាទេ?»

ផានូទើបនឹងដឹងថា ការចូលបន្ទប់ទឹកពេលនេះគឺដើម្បីងាយស្រួលនិយាយទូរសព្ទពីបងធំកាងសាលា ដោយមិនឲ្យអង្គរក្សនៅខាងក្រៅទាំងពីរប្រាណអាចស្តាប់ឮបាន។

«អាឡូ! ជម្រាបសួរ! តើនេះ បងឈុនរាជ កំពុងនិយាយ? ចាសៗ ពេលនេះដាកំពុងនៅក្នុងបន្ទប់ទឹកស្រី! ដូចដាជម្រាបបងមុននេះ នៅខាងក្រៅតាមឆាត គឺអ្នកយាមកំពូលរំខានពីរនាក់ហ្នឹងតាមដានមិនឲ្យបាត់ដានតែម្តង! ពេលនេះសង្ស័យកំពុងនៅក្បែរៗបន្ទប់ទឹកនេះឯងណាបង! បងចាត់ការឲ្យដាផង!»

ផានូ ក្រពាត់ដៃហួសចិត្ត ពេលឃើញមិត្តភ័ក្តិញញឹមញញែមពេលនិយាយទូរស័ព្ទជាមួយជើងកាងសាលា។

ភាគទី១០

…នៅក្នុងគេហដ្ឋានលោកឧត្តមសេនីយ៍ថ្ងៃនេះ ហាក់ចម្លែកបន្តិច ដោយគ្រប់គ្នាមកជុំគ្នានៅបន្ទប់សាឡុងតែម្តង។

ឧត្តមសេនីយ៍ ឌិត សាម៉ុន មិនមាត់មិនក តែម្ដាយនាងដែលអង្គុយលើសាឡុងដែរនោះធ្វើមុខក្រញូវ...

«អង្គុយចុះមកឯកមាន និងចិត្រា! ហឿនរកប្រេងមកលាបមុខមាត់ឲ្យពីរនាក់នេះ!»

ពេល ពូហឿន រវៀសរវៃដើរទៅរកប្រអប់ថ្នាំពីអ្នកម៉ាឡាដែលហុចមកឲ្យ ផានូនិងអមរាដានៅលើសាឡុងម្ខាងទៀត លបមើលមកអង្គរក្សទាំងពីរទាំងអស់សំណើចដល់ថ្នាក់ទប់ស្ទើរមិនចង់បាន។

«អង្គរក្សអី បើត្រូវគេវាយប៉ោងមុខ ប៉ោងមាត់អស់ហើយ?»

ជំទាវ រ៉ាស៊ី និយាយទាំងមិនពេញចិត្ត ពេលឃើញមុខមាត់ ឯកមាននិងចិត្រា ពោរពេញទៅដោយស្នាមក្រហមនិងប៉ោងហើម។

ពេលឧត្តមសេនីយ៍សម្លឹង ប៉ូលិសឈ្មោកមុខទាំងពីរមិនមាត់មិនក លោកជំទាវបញ្ចេញកំហឹងបន្ថែមមួយជាន់ទៀត៖

«បងសាម៉ុន សង្ឃឹមអីដែលថាពីរនាក់នេះ ការពារកូនដាបាន? ឲ្យគេទៅធ្វើការនៅស្នងការកាន់ឃ្លាំង កាន់សម្ភារអីវិញទៅ! ទន់ខ្សោយណាស់!  ម៉ាឡាជូនសោហ៊ុយ ពួកគេទិញថ្នាំលេបទៅ ហើយស្អែកមិនបាច់មកទៀតទេ សម្រាកព្យាបាលខ្លួនចុះ!»

បុរសទាំងពីរជ្រប់មុខមិនចេញស្ដី ធ្វើឲ្យអមរាដាលបមើលស្ថានភាពពួកគេហើយ នឹកអាណិតសន្សឹមៗ ដែលមកត្រូវរងគ្រោះព្រោះស្នាដៃខ្លួន។

នាងខំសម្រួលទឹកមុខ ហើយងាកសម្លឹងផានូ ក៏ឃើញភាពបន្ទោសចេញពីកែវភ្នែករបស់មិត្តក្នុងន័យថា «ឯងនេះ! គេតាមការពារសោះ លេងគេធ្ងន់ដៃម្ល៉េះ?»

«មិនទាន់ឲ្យអ្នកណាទៅណាបានទាំងអស់ ខ្ញុំត្រូវការដឹងរឿងហេតុពិត ពីដើមដល់ចប់!»

សំឡេងឧត្តមសេនីយ៍ មួយឃ្លានេះ ធ្វើឲ្យនារីអភិជន ទាំងទ្វេប្តូរពីអាណិតមកជាបុកពោះ។

ក្រសែភ្នែកផានូដែលវាត់មករកមិត្ត ហាក់ចង់ប្រាប់អមរាដាទៀតថា «ឯងត្រូវឃុំនៅផ្ទះលែងបានទៅរៀនមិនខាន បើឲ្យប៉ាឯងដឹងថាកូនគាត់ថ្លើមពាសមេឃលេងចូលសុទ្ធតែជើងកាងសាលា!»

«កូនចង់ឡើងសម្រាកហើយប៉ាម៉ាក់!»

នាងនិយាយរំអួយៗ ហើយមុខចាប់ផ្ដើមស្លេកស្លាំង។

«ទៅចុះកូន!»

ជំទាវ វ៉ាស៊ី អនុញ្ញាត ទោះបីជាប្ដីនៅមុខក្រញូវក្ដី។

ស្រីៗទាំងទ្វេបានឱកាសរត់ប្រែនចេញក្រៅបាត់ ធ្វើឲ្យលោកសាម៉ុននិយាយឌឺភរិយាដោយមុខស្មើ៖

«កុំស្មានថាអ្នកដែលលេងល្បិចធ្វើបាបអង្គរក្សខ្ញុំបានរួចខ្លួនស្រួលៗឲ្យសោះ!»

គាត់ថាហើយបក់ដៃហៅអង្គរក្សកម្សត់ទាំងទ្វេឲ្យក្រោកមកតាម ហើយដើរសំដៅបន្ទប់តូចមួយខាងឆ្វេងនោះ។

នៅក្រោមទឹកមុខពេញដោយការ តវ៉ាមិនសុខចិត្ត លោកជំទាវ វ៉ាស៊ី ដើរទៅតាមពីក្រោយប្ដីហើយពោលបន្ថែម៖

«ការពិតចេញឡើងនៅនឹងមុខហើយ រកវិធីការពារកូនចៅខ្លួនថាល្អទៀត? អីក៏កាន់ជើងម៉េះ

ឯកឧត្ដម? កូនចៅលោកមានសមត្ថភាពដែរអត់? ចេញធ្វើអ្នកការពារបានពីរបីដង កើតរឿងបានភ្លាមនៀក?»

ឧត្ដមសេនីយ៍ ឱត សាម៉ុន មិនខ្វល់និងសំណួរភរិយា។

គាត់រុញទ្វារបិទមិនចង់ឲ្យពួកអ្នកផ្ទះឮការសន្ទនានេះ ហើយចាប់ផ្ដើមចាក់សំណួរទៅរកប៉ូលិសជ្រប់មុខទាំងទ្វេដែលឈរឆ្អឹងកណ្ដាលបន្ទប់.

«និយាយរឿងពីដើមដល់ចប់ប្រាប់ខ្ញុំ!»

ឯកមានមើលមុខចិត្រា។ លុះឃើញមិត្តនៅស្ងៀម មិនព្រមហាមាត់ Hacker ក៏សម្រេចចិត្តនិយាយជំនួស៖

«ដំបូងអ្នកនាងអមរាដា ឃើញពួកខ្ញុំឈរការពារ គាត់ខឹងខ្លាំង ហើយហាមមិនឲ្យពួកខ្ញុំចូលជិត! ពេលនោះអ្នកនាងផានូថា ប្រសិនបណ្ដោយឲ្យអ្នកនាងអមរាដាខឹងខ្លាំងអាចនឹងមាន

រឿងធំ អ៊ីចឹងពួកខ្ញុំក៏មិនហ៊ានចូលក្បែរតែសម្លឹងមើលគាត់ពីចម្ងាយរហូត! ដំបូងគាត់ឆាតទូរស័ព្ទក្រោយមកក៏នាំគ្នាចូលបន្ទប់ទឹកបាត់ទៅ! គាត់ចូលជាងកន្លះម៉ោងនៅតែមិនឃើញចេញ ពួកខ្ញុំសង្ស័យខ្លាចមានរឿង! មានSMS មួយផ្ញើមកថាមានស្រីពីរនាក់ មានរឿងក្នុងបន្ទប់ទឹក ពួកខ្ញុំក៏ស្ទុះរត់ចូលទៅ! ភ្លេចគិតថាជាបន្ទប់ទឹកស្រីៗ ក៏...ត្រូវស្រីៗព្រួតវាយ!»

ឯកឧត្តមដឹងជាស្រេចថានេះជាល្បិចប្រភេទអ្វី?

គាត់ងក់ក្បាលផ្ងក់ៗ ហើយងាកទៅរកជំទាវ។ ជំទាវនោះក៏ទំនងភ្ញាក់ខ្លួនដឹងការពិតកូនស្រីខ្លួនខូចកម្រិតណា នៅពេលនេះបានជាគាត់ខំខ្ទប់មាត់ កុំឲ្យការអស់សំណើចផ្ទុះចេញ។

ឯកឧត្តមឆ្លៀតពេលឌឺប្រពន្ធ៖

«មិនដឹងថាកូនចៅខ្ញុំ អសមត្ថភាព ឬមួយកូនស្រីអ្នកខ្លះ ទំយើទៀងខូចអស់ដោយសារម្ដាយ?»

ជំទាវសម្រួលទឹកមុខវិញធ្វើដូចមិនខ្វល់។ គាត់តបវិញដោយទឹកមុខស្មើធេង៖

«បើជាអង្គរក្សឆ្លាតវៃដែរ ដឹងថាបន្ទប់ទឹកស្រីចូលធ្វើអី???»

ឯកឧត្តមសើចខឹក ទាំងក្ដៅចិត្ត ហើយនិយាយ ឌឺដងវិញដូចគ្នា៖

«អង្គុយចុះ ឯកមាន ចិត្រា! ហើយមើលអាលេខ SMS នោះរកមុខ អាអ្នកនៅពីក្រោយល្បិចនេះ ឲ្យខ្ញុំភ្លាម!»

បានដូចចិត្ត ឯកមានរាយការណ៍រហ័សដូចផ្លេកបន្ទោរ៖

«ឈ្មោះឈុនរាជជាបងធំកាងសាលាទាន!»

ដល់វេន លោកជំទាវភ្ញាក់ដូចធ្លាក់ថ្លើមក្អុក ហើយបើកភ្នែកធំៗ។ ស្មានមួយរយដងក៏មិនដឹងថាកូនស្រីមានល្បិចវាយប្រហារអង្គរក្សដែលឪពុកឲ្យតាមការពារ ហើយមានអ្នកនៅពីក្រោយជាមេកាងសាលាទៀត។ គាត់នឹកឃើញភ្លាមដល់ទឹកមុខស្លេកស្លាំងរបស់កូនទោល «កូនចង់ឡើងសម្រាកហើយប៉ាម៉ាក់!»។

ស្ថានភាពគាំងនិយាយមិនចេញរបស់លោកជំទាវ ធ្វើឲ្យឯកឧត្តមរឹតតែបានចិត្ត។ គាត់និយាយព្នៗទៅកាន់ឯកមាន៖

«ដាក់ក្រដាសប្ដឹងអាក្មេងនោះ ហើយនាំវាមកខ្ញុំចង់សួរនាំផ្ទាល់មាត់!»

ឯកមាន បង្ហាញទឹកមុខសោមនស្ស ចំណែកលោកជំទាវសសៀរខ្លួនគេចចេញ។

គ្រប់គ្នាដឹងថាស្ត្រីម្នាក់នេះកំពុងមានគោលដៅទៅកន្លែងណា។

ពិតដូចស្វាមីគិត ជំទាវរ៉ាស៊ីប្រញិបប្រញាប់ឡើងមករកក្រមុំទាំងទ្វេហើយខ្សឹបប្រាប់៖

«លោកប៉ាដឹងពីរឿងអ្នកកាងសាលាអីអស់នោះហើយ! ម៉េចកូនទៅសេពគប់ពួកអស់នោះកូនដា? អួះ ផានូម៉េចក៏មិនឃាត់គ្នា?»

នារីទាំងពីរ ក្រៅពីភ័យចច្រប់ចុះឡើងពេញបន្ទប់រកពាក្យអ្វីនឹងនិយាយតបម្ដាយមិនកើតឡើយ។ ដឹងថាសភាពការណ៍ថយក្រោយមិនបាន មានតែលេងផ្លូវកាត់ ដូច្នេះជំទាវ រ៉ាស៊ីក៏រកវិធីជួយកូនវិញ៖

«ខលទៅកូន! ខលទៅប្រាប់ម្នាក់ហ្នឹងថាប៉ាកំពុងឲ្យគេទៅហៅមកសួរនាំហើយ! ឲ្យគេប៉ុន្មានក៏ដោយ មិនឲ្យសារភាពថា កូននៅពីក្រោយរឿងហើមមុខពួកអង្គរក្សដាច់ខាត!»

អមរាដាសម្លឹងម្ដាយទាំងមុខស្លេក។ នាងងក់ក្បាលផ្ងក់ៗ ហើយលូករកទូរសព្ទមកចុច...

លោកឧត្តមសេនីយ៍នៅជាន់ខាងក្រោមឯណេះវិញ បានភរិយាចេញផុតក៏សើចស្រស់ល្ហួងចិត្តប៉ូលិសទាំងពីរ៖

«ប៉ិនទ្រាំណាស់! ទុកឲ្យស្រីៗទះកំផ្លៀងដល់ថ្នាក់នេះ! អូខេ! ល្អ! បើមិនរបួសហើមមុខ ម៉េចមានលេសបាត់ខ្លួនកើត? ស្អែកនេះចាំប្រាប់កូនដាថាពួកលោក នៅសំងំមើលរបួសមិនបានមកការពារទេ ចាំមើលគេចេញស្នៀតអីទៀត?!»

គាត់ងាកមករកឯកមាន ហើយនិយាយចូលដល់រឿងសំខាន់៖

«ខ្ញុំចង់ដឹងលំអិតពីអាកម្មវិធីអាថ៌កំបាំងស្អីគេនោះ!»

ឯកមាន បង្ហាញអ្វីមួយលើកុំព្យូទ័រ ដល់ឧត្តមសេនីយ៍ហើយពោលខ្សឹបៗ៖

«នេះជាPosterសមោសរពណ៌ព្រះចន្ទ! ជាទូទៅលិខិតនេះមិនមានកាលបរិច្ឆេទទេ! អ្នកចង់បានវាត្រូវផ្ញើប្រវត្តិរូបគ្រួសារទៅមុនហើយ ពេលណាដែលទទួលបានការអនុញ្ញាតឲ្យចូលរួម

ទើបទទួលបានលិខិតអញ្ជើញ ប៉ុន្តែដល់ថ្ងៃមែនទែនទើបគេប្រាប់ពេលវេលាទីកន្លែង! និយាយរួមជារឿងរាល់ថ្ងៃ បើអ្នកនាង អមរាដា បានទទួលឲ្យត្រៀមចូលរួម គេប្រាកដជាទាក់ទងមកជារឿយៗ!»

ឧត្តមសេនីយ៍ឯកឱិត សាម៉ុន ធ្វើមុខមាំហើយដកដង្ហើមធំ។

ចិត្រាដែលនៅស្ងៀមយូរហើយបកសំណួរមកវិញ៖

«អាថ៌កំបាំងរបៀបនេះធ្វើស្អី?»

ឯកមាន តបផ្ទួង៖

«ទាល់តែទៅសួរម្ចាស់កម្មវិធី!»

លោក ឱិត សាម៉ុន គ្រវីក្បាលបដិសេធចម្លើយរបស់ឯកមានហើយគាត់កាត់ក្តី៖

«វាមានចេតនា ក្នុងការចាប់ខ្លួនកូនស្រីអ្នកមានអស់ទាំងនោះ ដោយមិនឲ្យសល់ដាន!»

«ប៉ុន្តែ ពុំមែនមានន័យថាគ្រប់គ្នាដែលទៅសុទ្ធតែបាត់ខ្លួនទេទាន!»

ឯកមាននិយាយបន្ថែម ធ្វើឲ្យឧត្តមសេនីយ៍ទ្រចង្ការិះគិត។ ឯកមានឆ្លៀតឱកាសនេះ និយាយបន្ថែម៖

«គ្រាន់តែថា អ្នកបាត់ខ្លួនទាំងអស់ សុទ្ធតែធ្លាប់ទៅកម្មវិធីនោះ!»

«ហើយនៅថ្ងៃទៅចូលរួមនោះ ពួកគេទាំង៤ក៏លែងត្រឡប់មកវិញទាំងអស់?»

ចិត្រាសួរបញ្ជាក់បន្ថែម។

ឯកមានប្រើម្រាមចុចយ៉ាងញាប់ ឯលោកឧត្តមសេនីយ៍វិញក៏បកស្រាយលម្អិត៖

«អាចថា នៅទីនោះមិនមែនមានតែពួកគេបួននាក់ ហើយបួននាក់នេះក៏មិនមែន ចូលរួមពិធីនៅថ្ងៃជាមួយគ្នាដែរ! រយៈពេល៣២ម៉ោង គម្លាតពីការបាត់ខ្លួនម្នាក់ទៅម្នាក់យើងអាចកំណត់បានថា ពិធីនេះអាចថាមានធ្វើឡើងរាល់ថ្ងៃ គឺអ្នករៀបចំរៀបពេលផ្សេងគ្នាបំបែកមនុស្សឲ្យទៅកន្លែងផ្សេងៗគ្នា! វាអាចធ្វើវិធី ចម្រាញ់មនុស្សតាមរបៀបនេះ ហៅកូនអ្នកមានស្អាតៗទាំងអស់ ក្រោយមកក៏ចាប់ខ្លួនតែអ្នកណាដែលមានផ្នាំរោង! បើថ្ងៃណាមួយប៉ូលិស

មានតម្រុយស៊ើបដល់កម្មវិធីនេះក៏គ្មានភស្តុតាងឯណាគ្រប់គ្រាន់នឹងប្តឹងថា សមោសរពណ៌ព្រះចន្ទ ពាក់ព័ន្ធនឹងករណីបាត់ខ្លួនស្រីៗដែរ!»

ឯកមាន ងក់ក្បាលបង្ហាញឯកសារមួយផ្សេងពីScreen៖

«ខ្ញុំបានរករួចហើយ មើលបញ្ជីនេះទៅទាន! នៅថ្ងៃទាំងប៉ុន្មានដែលមានអ្នកបាត់ខ្លួន មានភោជនីយដ្ឋានសរុប៨៨កន្លែង ដែលបានកក់សម្រាប់ពិធីសមោសរ និងជប់លៀងលក្ខណៈសង្គមជាន់ខ្ពស់ ក្នុងចំណោមនោះសុទ្ធតែមានលិខិតអញ្ជើញ ដែលពុំមែនសម្រាប់សមោសរពណ៌ព្រះចន្ទ! ដូច្នេះ បើស៊ើបតាមនេះយើងនឹងអាចដឹងបានថា ពួកនោះប្រើឈ្មោះជាសមោសរមែន ប៉ុន្តែមិនបានប្រើភោជនីយដ្ឋាន ឬសណ្ឋាគារ កន្លែងសាធារណៈផ្សេងៗ ជាកន្លែងណាត់ជួបទេ!»

«ហេតុអ្វីក្មេងស្រីៗអស់នោះយល់ព្រមទៅ?»

លោកឱត សាម៉ុនសួររអុះៗ លាយឡំជាមួយនឹងទឹកមុខសញ្ជឹងគិតខ្វល់ខ្វាយ។

ចិត្រានិយាយវិញម្តង៖

«សំណួរគឺនៅត្រង់ថា តើនៅពេលបាត់ខ្លួន អ្នករងគ្រោះបានចូលរួមពិធីពិតមែន ឬមួយគ្មានពិធីទេវាជាអន្ទាក់ឲ្យពួកនាងទៅ ហើយបាត់ដានតែម្តង?»

ឧត្តមសេនីយ៍ងើបមុខមកវិញហើយសម្លឹងនាយស័ក្តិប្អូនទាំងពីរម្តងម្នាក់ៗ។

ឯកមានបិទកុំព្យូទ័រ ហើយបញ្ចេញយោបល់៖

«មហាវីនមានផ្ទះនៅភ្នំពេញ២ នៅកំពង់សោមមួយ និងសៀមរាបមួយ មណ្ឌលគិរីមួយ! នេះជាអចលនៈទ្រព្យដែលមានចុះបញ្ជីផ្លូវការតែប៉ុណ្ណោះ! ជននេះមានឈ្មោះពិត សុខា ដារាវីន ជាកូនកំព្រាតែម្នាក់គត់ សោយសុខលុយកាក់កេរ្តិ៍ពីឪពុកម្តាយធ្លាប់ជាអតីតមន្ត្រី គេគ្មានមុខរបរច្បាស់លាស់តែមានកម្មសិទ្ធិដីជាច្រើនរយហិតា ហើយត្រូវបានក្រុមហ៊ុនចិនជួលធ្វើកសិឧស្សាហកម្ម! ខ្ញុំជឿថា គេជាម្ចាស់ Account ដែលអ្នករងគ្រោះបានទាក់ទងមុនពេលបាត់ខ្លួន ដែល Account មានឈ្មោះបីផ្សេងៗគ្នាដូចជា ណាត់ជួប the moon Real Party និង NightNight ។ នៅក្នុងចំណោមកូដAccountទាំងបី មានខ្លះជាប់កំណត់ត្រា លេខទូរសព្ទដែលទិញដោយ អ្នកបើកឡានរបស់គេ មួយទៀតពីជំនួយការគេឈ្មោះដេវីដ!»

ចិត្រាងក់ក្បាលនិយាយបន្ត៖

«យើងមិនអាចឲ្យវាដឹងខ្លួនបានទេ! មិនអ៊ីចឹងដូចលែងត្រីទៅក្នុងទន្លេ គ្មានថ្ងៃអាចរកឃើញវិញ!»

ឧត្តមសេនីយ៍ដកដង្ហើមធំ៖

«ហៅសួរមិនបាន! តាមដានមិនកើត មានច្រកអីចេញ?»

ពួកគេនៅស្ងៀម គាត់និយាយបន្ត៖

«ខ្ញុំនៅតែគិតមិនយល់ថាអាម្នាក់នោះវាប្រើវិធីអី បានជាស្រីៗទាំងនោះសុខចិត្តជឿវា ហើយទៅលួចលាក់ចូលរួមកម្មវិធីឆ្កួតយកនោះ! ថាអ្នកបាត់ខ្លួន ទីមួយចុះ គ្នាមិនដឹងរឿង ចុះអ្នកក្រោយៗ ដឹងរឿងមនុស្សបាត់ខ្លួនបន្តបន្ទាប់ ម៉េចនៅតែហ៊ាន?»

ចិត្រាស៊កសម្ដី៖

«ទំនងជាគ្មានអ្នកណាដឹងថា អ្នកបាត់ខ្លួន សុទ្ធតែបានពាក់ព័ន្ធនឹងកម្មវិធីសមោសរពណ៌ព្រះចន្ទ ទេមើលទៅ? ចំណែកសំណួរថាហេតុអីស្រីៗចង់ទៅកម្មវិធីនោះម្ល៉េះ? អាចថា គួរតែមានអ្នកណាម្នាក់ធ្លាប់ទៅចូលរួមមុន ហើយយកកម្មវិធីនេះមកផ្សព្វផ្សាយបន្ត?»

ឧត្តមសេនីយ៍ទំនងជាយល់ស្របគំនិតនេះមួយទំហឹង។ គាត់ទះដៃផាំងហើយសរសើរ៖

«ត្រូវ! ច្បាស់ជាមានមេអណ្ដើក ដែលលាក់មុខ ហើយដឹងរឿងអស់ទាំងនេះច្បាស់!»

ចិត្រាងក់ក្បាល ចំណែកឯកមាន គិតចុះគិតឡើងម្នាក់ឯង ទុកឲ្យលោកឱត សាម៉ុននិយាយបន្ត៖

«វាលាក់មុខបាន ទាល់តែកុំចេញមកទាក់ម៉ូយថ្មី!»

ឯកមាន ញញឹមព្រោះយល់សម្ដីបុរសនេះ។

គាត់ហាក់លែងខឹងសម្បារបែរ ដូរមកជារីករាយ ពេញដោយសេចក្ដីសង្ឃឹម។ ឧត្តមសេនីយ៍និយាយបន្តដោយខ្សឹបៗ៖

«ប្រាប់មក ថាលោកចង់បានLaptopរបស់កូនដា? ទូរស័ព្ទដៃ?»

ឯកមានញញឹមស្រស់ព្រោះជួបមនុស្សយល់ចិត្ត។ គេនិយាយទាំងគ្រវីក្បាល៖

«អត់បានការទេ តែបើអ្នកនាងព្រមប្រើWifiនៅកន្លែងសាធារណៈ ខ្ញុំអាចចូលលួចយកទិន្នន័យបាន១០០ភាគរយ!»

ឧត្តមសេនីយ៍ញញឹមដៀងភ្នែកសម្លឹងHacker។ គាត់ដឹងថាបុរសនេះ ចេះច្បាស់លើជំនាញរបស់គេ ថែមទាំងដឹងថា Wifi ផ្ទះនេះមិនអាចជ្រែកចូលបាន ដូច្នេះបានជាបញ្ជៀសឲ្យកូនស្រីគាត់ប្រើចរាចរណ៍Internetសាធារណៈដែលគ្មានប្រពន្ធការពារ។

«ខ្ញុំរៀបចំឲ្យ!»

គាត់និយាយទាំងទះស្មាឯកមាន។

ឧត្តមសេនីយ៍ក្រោកចេញ បន្សល់ឲ្យឯកមាននូវស្នាមញញឹម លាយជាមួយចិញ្ចើមញាក់រកមិត្ត បង្កប់នូវភាសាសម្ងាត់ថា«៥រយលានរៀល ជារបស់អាមានហើយពេលនេះ!»

វគ្គ ចម្លើយបងឈុនរាជ

ឧត្តមសេនីយ៍អង្គុយក្នុងបន្ទប់ម៉ាស៊ីនត្រជាក់ដែលខាងសាលារៀបចំឲ្យ។

ឯកមាននិងចិត្រានៅឈរពីក្រោយខ្នងគាត់ ចំណែកនាយកសាលា អង្គុយធ្វើមុខជ្រប់ពេញដោយការអៀនខ្មាស។

ស្នូរគោះទ្វារបញ្ចប់បរិយាកាសមិនល្អ ហើយយុវជន ទាបកន្ទុញម្នាក់រុញទ្វារបង្ហាញខ្លួន...

ឧត្តមសេនីយ៍សម្លឹងទៅរាងទាបតូចរបស់គេ គាត់មានអារម្មណ៍ថាកើតតប់ប្រមល់ ក៏ងាកមកដេញដោលលោកសកលវិទ្យាធិការ៖

«បងពិនិត្យ! ពេលណាក្មេងឈ្មោះឈុនរាជមក?»

«គឺខ្ញុំនេះហើយពូ!»

យុវជន ទាបខុសខ្នាតឆ្លើយមកធ្វើឲ្យឧត្តមសេនីយ៍ភ្ញាក់សឹងបះសក់។ គាត់ចង្អុលទៅសាមីម្ចាស់សម្ដី មុនពេលងើបសម្លឹងមុខនាយកដើម្បីបញ្ជាក់។

លោកពិនិត្យងក់ក្បាល មុនពេលបញ្ជាក់៖

«គេនេះហើយ ឈុនរាជ!»

ពេលដែលគ្រប់គ្នាកំពុងឡិងឡង់ សកលវិទ្យាធិការងាកមកសម្លក់ហើយបន្ទោសខ្សឹបៗ៖

«ឈរឲ្យត្រង់! ចាំឆ្លើយសំណួរលោកផ្កាយបី ហាមបាត់ម៉ាពាក្យណា! ឮ???»

«សូមគោរពទាន!»

បងឈុនរាជ គោរពភ្លែតទាំងបញ្ចេញអាការៈ ញញឹមញញែមហាក់សប្បាយចិត្ត ពេលដឹងថាអ្នកស្លៀកស៊ីវិលម្នាក់នេះជាប៉ូលិសហើយមានសក្តិធំផង។

ឧត្តមសេនីយ៍ដៀងភ្នែក លួចសម្លឹង ប្រអប់ទឹកដោះគោជូរសជាតិផ្លែស្ត្របឺរី ដែលលៀនចេញពីហោប៉ៅខោគេ។ ធ្វើឲ្យនាយកសាលា ប្រញាប់ប្រញាល់ ស្តីបន្ទោសខ្សឹបៗម្តងទៀត៖

«ធំប៉ាប៉ិនហ្នឹងហើយ ផឹកទឹកដោះគោជូរទៀត!?»

«ខ្វះជាតិទឹកដោះលោកគ្រូ!»

គេឆ្លើយលឿនធ្វើឲ្យ ឯកមានទប់មិនជាប់សើចខឹកដំណាលនឹងឧត្តមសេនីយ៍។

នាយ ឈុនរាជ នេះកំប្លែងនិងចម្លែកសឹងអាចឲ្យប៉ូលិសទាំងបីភ្លេចគិតថាខ្លួនមកទីនេះដើម្បីអ្វី?

ពេលដែលសកលវិទ្យាធិការ កំពុងច្បាមសក់ខ្លួនឯង ទាំងស្លាក់និយាយមិនចេញនោះ លោកឱត សាម៉ុននិយាយមួយៗទៅកាន់យុវជនខុសខ្នាត៖

«អង្គុយចុះមក! ពូមានសំណួរខ្លះ!»

«សហការរីករាយ!»

គេថាហើយអង្គុយរឹង ព្រមទាំងលើកកំប៉ុងភេសជ្ជៈមកចោះបឺត។

«ក្មួយល្បីឈ្មោះជាងគេនៅមហាវិទ្យាល័យនេះ?»

គេនោះ ញញឹមញញែម ឈប់ក្រេបភេសជ្ជៈ ហើយតបវិញស្រួយស្រេះ៖

«អរគុណដែលពូប៉ូលិសសរសើរ! ខ្ញុំចង់ធ្វើប៉ូលិសណាស់ តែរូបរាងខ្ញុំត្រូវគេរើសអើង!»

ឧត្តមសេនីយ៍ក្រពាត់ដៃហើយនិយាយ៖

«ទោះមិនបានធ្វើប៉ូលិស ក៏មិនគួររើសយកអាជីពកាងសាលាដែរ?»

លោកពិនិត្យងាកមុខចេញ មិនហ៊ានប្រឈមមុខត្រង់ៗ នឹងការស៊កសៀតនេះ ប៉ុន្តែនាយល្អិតវិញមិនបានថមថយឡើយ គេប្ដូរទឹកមុខទៅជាងឿងឆ្ងល់ លាយបដិសេធឃ្លាខាងដើម មុនពេលនិយាយ ដោះសាដោយមិនបង្អង់វិញ៖

«ពាក្យនេះធ្ងន់ណាស់ សម្រាប់យុវជនស្លូតត្រង់ដូចខ្ញុំ!»

ឧត្តមសេនីយ៍ វេភ្នែកទាំងញញឹម សម្លឹងរាងកាយយុវជននេះ ពីលើដល់ក្រោម។ គេនេះសម្ដីចច្រិច សមល្មម នឹងមាឌខុសខ្នាតរបស់គេ។ គាត់អាចមានវិធីច្រើន ក្នុងការកំដរគេលេងសើច ប៉ុន្តែទាស់ត្រង់ពេលនេះ គាត់គ្មានវេលាច្រើនរង់ចាំ ដូច្នេះលោកឧត្តមសេនីយ៍ចង្អុលទៅក្រោយខ្នងខ្លួនជំនួសស្រដី។ យុវជនទាបសម្លឹងហួសទៅតាមសញ្ញា ឃើញចិត្រានិងឯកមានដែលកំពុងធ្វើមុខមាំ។

នាយល្អិតសម្លឹងចុះឡើង ជាមួយទឹកមុខហាក់មិនដឹងរឿងអ្វី ហើយចាប់ផ្ដើមងាកមកប្រាប់អ្នកសួរនាំវិញ៖

«តាមបទពិសោធន៍របស់ខ្ញុំ ពីរនាក់នេះត្រូវប្រពន្ធទះ ម៉េចក៏ម្នាក់២០កំផ្លៀងដែរ!»

ឯកមាន ផ្លុំមាត់ទប់កំហឹងព្រោះយល់ថា ខ្លួនកំពុងត្រូវមនុស្សល្អិតឌឺ។

ចំណែក ចិត្រាធ្វើមុខស្មើធេង ព្រោះជឿថាឧត្តមសេនីយ៍ និងផ្ដល់មេរៀនដល់មនុស្សល្អិតនេះ។

«ឯងប្រាប់ល្បិចអីដល់កូនស្រីខ្ញុំ ឲ្យបោកអង្គរក្សខ្ញុំរត់ចូលបន្ទប់ទឹកស្រីៗម្សិលមិញ?»

គេធ្វើមុខដូចរកនឹក ហើយទើបផ្ទុះសំណើចយ៉ាងវែង ធ្វើឲ្យឧត្តមសេនីយ៍ទប់កំហឹងដៀងភ្នែកទៅរកនាយក។ លោកនាយកគិតពីជ្រប់មុខមិនហ៊ានសម្លឹងតបនឹងភ្ញៀវវិញឡើយ។

«បើឯងមិនឆ្លើយសំណួរនេះឲ្យត្រឹមត្រូវ ខ្ញុំនឹងនាំឯងទៅស្នងការ!»

គាត់និយាយតិចៗ ព្រោះមិនចូលចិត្ត កិរិយាខុសប្រក្រតី របស់មនុស្សល្អិត។ តែក្មេងនេះហាក់មិនញញើនគេតបវិញ៖

«ខ្ញុំគ្មានកំហុសអ្វីទាំងអស់ទាន!»

«នៅពីក្រោយ ការបង្ករបួសស្នាមប៉ុណ្ណឹងហើយ នៅចង់ក្រឡាស់យករួចខ្លួន!»

ជនល្មិតស្ការដៃជើងនិយាយៈ

«នៅមហាវិទ្យាល័យនេះ អ្នកណាក៏ដឹងដែរថាឈុនរាជខ្ញុំនេះ ជាមនុស្សស្រលាញ់និស្សិត ជួយការពារពួកគេ ហើយសិស្សប្អូនអមរាដាមានទុក្ខលំបាកដែលឪពុកដាក់អង្គរក្សមកតាមសឹងចប់ដង្ហើមរៀនមិនកើត ខ្ញុំក៏រកវិធីជួយពន្យល់នាងតាមទូរស័ព្ទ ដឹងអីកំពុងពន្យល់នាងប្រាប់ថា ជួយហៅអង្គរក្សផង នាងវិលមុខខ្លាំងត្រូវការទៅផ្ទះ ខ្ញុំCallទៅ គេមិនលើក ខ្ញុំក៏SMSទៅ!»

ចិត្រាតបភ្លាមៈ

«មិនសមហេតុផល! ខ្ញុំជាអង្គរក្ស គ្មានសិទ្ធិទទួលទូរស័ព្ទចម្លែក ក្នុងពេលបំពេញភារកិច្ចទេ! ហើយបើអ្នកនាងមានធុរៈគួរតែខលមកខ្ញុំខ្លួនឯង!»

«ប្រាប់ថាគាត់វិលមុខនិយាយទៀតមិនបាន បានជាពឹងខ្ញុំ!»

ឯកមាន វិញម្តង គេសួរសង្វើញៈ

«បងល្មិតឯង ប៉ិនរកពាក្យដោះសាណាស់! ចុះអ្នកនាងផានូម្នាក់ទៀត ធ្វើអីបានជាមិនព្រមចេញមកហៅពួកខ្ញុំ?»

«អាហ្នឹងទាល់ទៅសួរនាងខ្លួនឯង! ខ្ញុំម៉េចដឹង?»

ភាគទី១១

ឧត្តមសេនីយ៍សម្គាល់ឃើញថា ក្មេងខុសខ្នាតម្នាក់នេះ ហាក់មានសមត្ថភាពស្ទាត់ជំនាញក្នុងការឆ្លើយដោះសា ហើយទោះបីជានាំគេទៅចោទពីបទរុកគួនឲ្យមានអំពើហិង្សាក៏ដោយ ក៏ប្រហែលជា ពិបាកក្នុងការចោទប្រកាន់នាយ។

លោក ឌិត សាម៉ុន ដៀងភ្នែកទៅមើលលោកពិនិត្យ ជានាយកសាលាវិញ។ បុរសនោះសម្លឹងកម្រាលតុជំនួសឲ្យការហ៊ានប្រឈមនឹងមនុស្សម្នា។ ប្រការនេះធ្វើឲ្យប៉ូលិសចំណាស់ដឹងថាគាត់អាចជាគោលដៅថ្មីមានប្រយោជន៍។

«សេវាកម្ម ការពារក្នុងសាលាបង់ពន្ធប៉ុន្មានដែរ? ខ្ញុំអាចសរសេរពីប្រការនេះ ហើយដៃគូសហការឧបត្ថម្ភសាលានេះគេនឹងចុះមកសើរើ!!»

«សូមបង សាម៉ុន យោគយល់ផង! ខ្ញុំសន្យាប្រៀនប្រដៅ ឈុនរាជសាជាថ្មី!»

ទោះបីលោកពិនិត្យ ហាក់ទោរទន់ សុំការយោគយល់ តែនាយឈុនរាជ នៅតែរក្សាជំហរមិនខ្លាចក្រែងដដែល។ ដូច្នេះលោក ឧត្តមសេនីយ៍ដៀងភ្នែកត្រឡប់មករកគេជាមួយវាចាដៀមដាមៈ

«បងពិនិត្យភ័យធ្វើអី ខ្ញុំមានថាធ្វើអីកូនប្រុសបង? ខ្ញុំគ្រាន់តែសរសើរទេពកោសល្យគេ!»

ឈុនរាជ ធ្វើមុខក្រញូវពេលឮឃ្លានេះពីមាត់ឧត្តមសេនីយ៍។ គេនិយាយដោយមិនកោតក្រែង ៖

«ខ្ញុំអរណាស់ បានអ្នកធំសរសើរ តែខ្ញុំសុំកែតម្រូវរឿងមួយ ខ្ញុំគ្មានប៉ាទេ! តាំងពីម្ដាយខ្ញុំខូចទៅ ខ្ញុំជាក្មេងកំព្រាសុទ្ធ!»

លោកនាយក ខំងាកមុខចេញពីកែវភ្នែកគ្រប់គ្នាដែលសម្លឹងមក ចំណែកយុវជនខុសខ្នាតនៅតែរក្សាភាពខែងរឹងធ្វើឲ្យឧត្តមសេនីយ៍ លើកដៃពត់ខ្លួនប្រាណ បម្រុងក្រោកទាំងមាត់ពោល ៖

«អ៊ីចឹងល្អហើយ! ខ្ញុំចង់បានក្មេងកំព្រាដែលមានសមត្ថភាពរៀនសាលាថ្លៃយ៉ាងនេះ មកជាប៉ូលិសជួយខ្ញុំ!»

ពាក្យថាចង់បានមកជាប៉ូលិសជាព្រួញដែលដោតបេះដូងមនុស្សតូចល្អិតម្នាក់នេះឲ្យបើកភ្នែកធំៗ។ ទាន់ពេលអារម្មណ៍គេកំពុងរំញោច គាត់និយាយបន្ថែមចុងក្រោយៈ

«ចំណែកសាលានេះធ្វើឲ្យអង្គរក្សខ្ញុំរងរបួស ខ្ញុំបានថតទុកមុខរបួសស្លាកស្នាម មានលិខិតវេជ្ជ សាស្ត្រយោងគ្រប់គ្រាន់តាមច្បាប់ ខ្ញុំត្រូវការកសាងពាក្យប្ដឹងទៅតុលាការ!»

គាត់ចាកចេញទាំងបោះនាមប័ណ្ណលើតុព្រមជាមួយសម្ដីបង្ហើយៈ

«ខ្ញុំនិយាយម៉ាត់ណាម៉ាត់ហ្នឹង ខ្ញុំពេញចិត្តទេពកោសល្យក្មួយណាស់ ខ្ញុំថាយកឯងធ្វើប៉ូលិស ខ្ញុំប្រាកដជាយក ចំណែករឿងសិស្សស្រីៗនៅទីនេះ ព្រួតវាយកូនចៅខ្ញុំ ខ្ញុំត្រូវតែទូទាត់ជាមួយសាលារកឫសគល់ដូចគ្នា!»

បុរសចំណាស់ចាកចេញទាំងមិនបានលា ធ្វើឲ្យឈុនរាជអង្គុយធ្វើមុខក្រញូវ ឈ្ងោកមុខគិតចុះឡើង មុនពេលសម្រេចចិត្តរត់ទៅតាម ពេលដែលប៉ូលិសទាំងបីដើរដល់ជណ្ដើរទៅហើយ។

«ពូកុំប្ដឹងប៉ាខ្ញុំបានអត់?»

ឧត្ដមសេនីយ៍ញញឹម ហើយឈប់នៅត្រឹមមាត់ជណ្ដើរ ងាកមកសម្លឹងយុវជននេះ មុនពេលសម្លឹងឆ្លាយហួសទៅឪពុកគេ ដែលកំពុងឈរនៅក្បែរទ្វារទីចាត់ការសាលា។

ឈុនរាជបន្តនិយាយ៖

«ខ្ញុំសុខចិត្តសុំទោសអង្គរក្សពូពីរនាក់នេះ ហើយសន្យាតាមការពារសុវត្ថិភាពអមរាជា មិនឲ្យបាត់មួយសរសៃសក់!»

ចិត្រាដឹងថា ឧត្ដមសេនីយ៍ដឹងពីប្រវត្តិមិនត្រូវខ្សែគ្នារវាងឪកូនទាំងពីរ បានជាគាត់អាចចូលមកកាន់ទីនេះជាមួយសេណារីយោមួយនេះបាន។ ចំពោះមុខពេលនេះ គឺនាយស័ក្ដិបួនដឹងច្បាស់ពីអ្វីដែលឧត្ដមសេនីយ៍ ឱត សាម៉ុន ចង់បានពីនាយឈុនរាជ។

ដូចអ្វីដែលវរសេនីយ៍ត្រី ជាតិ ចិត្រាបានគិតមែន លោកឱត សាម៉ុន និយាយខ្សាវៗដាក់យុវជនមាឌតូច៖

«ពូមិនចង់ឲ្យឯងការពារទេ តែពូចង់ឲ្យឯងធ្វើការផ្សេងជាមួយអមរាជា ហើយលក្ខខណ្ឌដំបូងគេគឺមិនឲ្យនាងដឹងខ្លួនថាពូមករកឯងជាដាច់ខាត!»

ឈុនរាជធ្វើភ្នែកស្លឹសម្លឹងបុរសចំណាស់។ គាត់មិចភ្នែកតិចៗដាក់គេមុនពេលទះស្មាស្រាលៗហើយចាកចេញ។

នៅលើរថយន្ត...

ចិត្រា បើកឡានបណ្តើរ សំងំពិចារណាពីគំនិតឧត្តមសេនីយ៍ដែលនឹកឃើញមកប្រើប្រាស់អ្នកកាងសាលាដ៏គួរឲ្យចង់សើចម្នាក់នេះបណ្តើរ ប៉ុន្តែនៅបាំងខាងក្រោយ ឯកមានមិនបានព្យាយាម អត់ធន់ច្រើនដូចមិត្តទេ។ គេសួរភ្លាមៈ

«អ្នកលេងកន្ត្រៃឈុនរាជនេះ អាចធ្វើឲ្យខូចការយើងទេទាន?»

ឧត្តមសេនីយ៍ងាកសម្លឹងស្នាមជាំដ៏គួរឲ្យអស់សំណើចលើមុខ Hacker ។ គាត់ប្រឹងទប់សំណើចហើយឆ្លើយតបៈ

«ការស្ទៀមមិនតដៃបណ្តោយឲ្យពួកនិស្សិតស្រីវាយជាំមុខនេះ មិនអត់ប្រយោជន៍ទេ ខ្ញុំសន្យានិងលោក ឯកមាន!»

Hacker នៅស្ទៀមសម្លឹងមកឧត្តមសេនីយ៍ ដែលកំពុងញញឹមស្រស់ហាក់សប្បាយចិត្តនឹងអ្វីម្យ៉ាងជាសម្ងាត់។ គាត់ឃើញភ្នែកក្រឡង់ៗ ហាក់មិនទាន់យល់ន័យតាមកញ្ចក់ក៏និយាយបន្ថែមៈ

«អ្នកទាំងពីរ យកលេសថាទៅសម្រាកព្យាបាលរបួសទៅ! កូនស្រីកំហូចខ្ញុំនឹងចេញទៅ Party ជាមួយផានូ! ខ្ញុំឲ្យគេផ្សព្វផ្សាយតម្រុយអាក្រក់មួយចំនួនទៀតទាក់ទងនឹងអ្នករងគ្រោះទាំង៤ ក្មេងស្រីៗពីរហ្នឹង គេច្បាស់ជាភ័យ ហើយទៅពិគ្រោះជាមួយឈុនរាជ!»

ចិត្រារភ្នែកសម្លឹងលោកឱត សាម៉ុនដែលអង្គុយខាងមុខទន្ទឹមខ្លួន។ គេយល់អ្វីដែលបុរសនេះកំពុងគិត ប៉ុន្តែឧត្តមសេនីយ៍នៅតែព្យាយាមពន្យល់បន្ថែមៈ

«ហើយមិនយូរប៉ុន្មាន កូនខ្ញុំនឹងត្រូវពួកមនុស្សខាងណោះទាក់ទងមក!»

ចិត្រាងក់ក្បាលយល់ស្រប ចំណែក Hacker ដែលនៅបាំងក្រោយ ខំលោអង្គុយកៀកមកខាងមុខឲ្យបានជិតអ្នកទាំងពីរ។

លោកឧត្តមសេនីយ៍ងៀងភ្នែកទៅរក ឯកមានវិញម្តងទាំងពោលប្រាប់ៈ

«ហើយ ខ្ញុំនឹងរៀបចំ ធ្វើម៉េចឲ្យកូនខ្ញុំចេញទៅប្រើ Wifi នៅក្រៅ!»

ឯកមានញញឹម...

វគ្គ អ្នកណានៅពីក្រោយពិធីសមោសរពណ៌ព្រះចន្ទ

«វ័យជំទង់គឺជាពេលវេលាដ៏អស្ចារ្យនៃជីវិត ព្រោះវាជាពេលដែលយើងត្រូវចំណាយលើមិត្តភាពដ៏ផ្អែមៗ នឹងសេចក្ដីស្រមៃល្អៗពេញបេះដូង!»

ស្នូរបោះសៀវភៅចោលទៅលើតុ បង្អាក់ការទន្ទេញចុះឡើងរបស់ផានូ។

នាងឈប់ញញឹមជាមួយទស្សនៈដែលខ្លួនកំពុងប្រឹងទន្ទេញឲ្យចាំរត់មាត់ ហើយដៀងភ្នែកមកប៉ះមិត្តល្អដែលក្រញូវ។

គេដឹងហើយថា អមរាដាកំពុងអន់ចិត្តរឿងអ្វី ដូច្នេះស្រីស្អាតផានូនៅតែបន្តទន្ទេញទៅមុខ៖

«បេះដូងរបស់ខ្ញុំ ពោរពេញទៅដោយការជឿជាក់ ជឿជាក់ថាខ្ញុំពិតជាមានទេពកោសល្យ មានចិត្តព្យាយាមនិងមានអនាគត...»

អមរាដាស្ដីឲ្យកាត់ផ្ទង៖

«អស្ចារ្យហើយនាង! សប្បាយដូចហោះបានគេយល់ព្រមទទួលទៅ Party ប្រុងទៅតែឯង?»

ផានូលើកសៀវភៅគ្របមុខ ធ្វើឲ្យអមរាដាតាមទាញចេញ បន្ទោសបន្ថែម៖

«យើងនឹងធ្វើជាឆ្អឹងទទឹងក! សមោសរនោះ យើងមិនបានទៅ ឯងក៏មិនបានទៅដូចគ្នា!»

ផានូដឹងថាមិត្តនិយាយងរង៉ក់លេងទៅតាមចិត្តដែលកំពុងតប់ប្រមល់ ព្រោះរហូតដល់ពេលនេះអមរាដា នៅមិនទាន់ទទួលបានលិខិតអញ្ជើញនៅឡើយ។ នាងសប្បាយព្រោះខ្លួនទើបតែបានទទួលថ្ងៃណាត់ទាំងពេលវេលានិងទីកន្លែងបានជាមិនប្រកាន់កាយវិការមិត្ត ថែមទាំងញាក់ចិញ្ចើមឌឺដង៖

«អ្នកខ្លះបាក់ទឹកចិត្តមែន?»

អមរាដាក្រញូវអង្គុយចុះក្បែរមិត្ត នាងដកដង្ហើមធំទាំងស្ដាយ។ បានចិត្តផានូឌឺបន្ថែម៖

«ឮថា គេនោះ មកបរិច្ចាគលុយនៅសាលារៀនអង្គការក្បែរគំនរសំរាមស្ទឹងមានជ័យស្អែកនេះ!»

នាងនិយាយខ្សឹបៗដាក់មិត្តផងបញ្ចេញភាពសប្បាយរីករាយតាមកែវភ្នែកផង។ អមរាក្រឡេកមកមិត្ត។ ចិត្តនាងហាក់ពេញចិត្តណាស់ដែលបានទទួលព័ត៌មាននេះ តែឃើញមិត្តដូចជាជ្រួលជ្រើមពេកនាងក៏ដឹងខ្លួនទាន់ហើយរៀបឫកពាធ្វើនឹងននិយាយវាហឹះ

«មានអីគួរឲ្យសប្បាយ? ព័ត៌មានបោកប្រាស់អស់ហ្នឹងឮមករាប់ភ្លេចហើយ! អ្នកណាក៏អួតថា Lorenzoមកចែកអំណោយដោយផ្ទាល់ដែរ តែតាមពិតសុទ្ធតែជា Promotion ទាក់ទាញភ្ញៀវឲ្យមកចូលរួមបរិច្ចាគជាមួយ ដល់មែនទែនគេឲ្យត្រឹមតែ Assistant មកសោះ!»

ផានូនៅតែញញឹមហើយវាចាតបរិញពេញដោយក្ដីសង្ឃឹមៈ

«ក្រែងម្ដងណោះ គេមកមែនទែនណា៎! កុំគិតអីមិនល្អពេកមើល!»

ផានូមិនឃើញមិត្តតបត នាងបុកស្មាអមរាដាហើយចំអន់ៈ

«មើលឯងចុះ! មានគូដណ្ដឹងហើយនៅវាយមាយទៀតហ្អេស? លោភម៉េះ?»

ទោះដឹងថាផានូចំអន់លេង អមរាដានៅតែកើតចិត្តខឹងពេលនឹកដល់បុរសនោះ។ នាងប្រែមុខក្រញូវនិយាយរអ៊ូមួម៉ៅៈ

«លើកឲ្យឯងចុះ ប៊ិ Roy ហ្នឹង! ឮតែឈ្មោះក៏ស៊យ!»

ផានូមិនតបត ព្រោះរវល់ពិនិត្យអ្វីម្យ៉ាងនៅលើអេក្រង់ ដែលទំនងជាកំពុងធ្វើឲ្យចិត្តនាងភ័យព្រួយ។ បើតាមទឹកមុខរបស់នាង អមរាដាអាចនឹងដេញដោលបន្ថែម ប៉ុន្តែនាងស្រាប់តែលើកវាមកបង្ហាញមិត្តតែម្ដង។

«រឿងហ្នឹងម៉េចទេ? អត់ចេះចប់សោះនៀក!»

ផានូនិយាយតិចៗដាក់កែវភ្នែកបារម្ភរបស់មិត្ត។ អមរាដាមិនបាច់ស្ដាប់ចប់ក៏ដឹងថានេះជាការបាត់ខ្លួនស្រីៗវ័យក្មេងស្អាតៗជាអ្នកនាងក្នុងត្រកូលអភិជនដែលកំពុងតែកក្រើករាជធានី។

ស្រីស្អាតទាំងពីរ រេភ្នែកមើលមុខគ្នាមិនមាត់មិនក មុនពេលអមរាដាងាកទៅក្រៅបង្អួច។

នាងដកដង្ហើមធំៈ

«ប៊ិអង្គរក្សហ្នឹង សុំច្បាប់បាត់ទៀត!»

ផានូកែទឹកមុខពីភ័យស្លេកមកជាញញឹមផ្ទាន់៖

«ក្រែងមិនចង់ឃើញគេហ្អី? ឥឡូវចេះភ័យដែរ?»

អមរាដាសម្រួលទឹកមុខធ្វើវាហី ហើយនិយាយបន្លប់៖

«អត់គេក៏មិនស្លាប់! នៅនាំតែទើសនាំតែសៅហ្មងចិត្ត! យើងនេះជាមនុស្សល្អ ពីណាមកធ្វើបាប មកចាប់យកទៅបំបង់បាយស្អី!»

ផានូក្រពាត់ដៃឱ្យដងវិញ៖

«ចង់មានន័យថាអ្នកទៅមុនៗសុទ្ធតែគេមិនមែនមនុស្សល្អ?»

«អានព័ត៌មានទៅ ស្តាប់គេផង! មកនិយាយយកឈ្នះចាញ់ទៅកើត?»

អមរាដាកេះមិត្តឲ្យអានព័ត៌មានពីដើមដល់ចប់ ដោយផានូកាន់តែអានទឹកមុខ កាន់តែកើតក្តីបារម្ភទៅជាលំដាប់ទៅតាមនោះដែរ។

នាងងាកមករកមិត្តឃើញអមរាដាកំពុងតែស្រាក់ម្រាមទាំង១០ ទប់ស្កាត់ក្តីកង្វល់ដូចគ្នា។

ផានូខ្សឹបសួរតិចៗ៖

«ហេតុអីមានសាក្សីឃើញថាមុនបាត់ខ្លួន ម្នាក់ហ្នឹងចូលសាឡនតែងខ្លួនដល់ទៅបីម៉ោង?»

អមរាដាប្រិចភ្នែកចុះឡើងជំអក់មិនឆ្លើយ តែផានូដឹងជាស្រេចថាមិត្តកំពុងគិតយ៉ាងណា។

«គេចេញទៅជប់លៀងហើយក៏បាត់ខ្លួនមែនដែរអត់?»

ផានូខ្សឹបៗសួរទាំងទុក្ខព្រួយពេញប្រៀបលើផ្ទៃមុខ។ អមរាដាក៏ចត់មាត់និយាយលែងចេញ មានតែគេចពីភ្នែកមិត្តហើយចាប់ផ្តើមអាការៈអន្ទះអន្ទែង។

«អមរាដា!»

គឺផានូ ដាច់ចិត្តហៅមិត្តតិចៗក្រោយពីបន្ទាយពេលនៅស្ងាត់ស្ងៀមទ្រាំច្របូកច្របល់បានបន្តិចក៏មុនពេលនិយាយដាច់ស្រេច៖

«ណ្ហើយ! បើចាំដល់ល្ងាចនេះ គេមិនជូនដំណឹងមកថាយល់ព្រមឲ្យឯងទៅ! យើងនឹងប្រាប់គេថាមិនទៅតែម្តង! ខ្ជិល! ទៅម្នាក់ឯងម៉េចទេ!»

អមរាជាបានដៃញញឹមឌឺដង៖

«ថាអីចេះខុស! ឃើញនៅចេះខ្លាចដែរ?»

ផានូសម្លឹងមិត្តជាមួយក្រសែភ្នែកបញ្ជាក់ថា នាងមិនមែនស្ថិតក្នុងអារម្មណ៍ឌឺដងលេងសើចទេ។

«នែ៎! ផានូ! ចាំយើងឲ្យអង្គរក្សពីរនាក់នោះទៅជាមួយឯង!»

ប៉ុន្តែផានូបែរជាដកដង្ហើមធំ បន្លាយពេលបន្តិចមុនពេលវាចាតបរិញ៖

«អ្នកបាត់ខ្លួនអស់ទាំងហ្នឹង ក៏មិនមែននាំអង្គរក្សទៅតិចដែរ ឯងដឹងអត់? ហើយនែ៎! ប៉ាឯងជាប៉ូលិសស្រាប់! ឯងគួរសួរគាត់! រឿងក្តីបាត់កូនស្រីអ្នកមានធំៗ គឺអង្គរក្សក៏បាត់ម្ចាស់ក៏បាត់រើយ!»

អមរាជាធ្លាក់ទឹកមុខទៅជាព្រួយបារម្ភ។ ទោះបីនាងកើតមកជាកូនស្រីអ្នកកាន់កាំភ្លើង មានសក្តិលើស្មានិងមានអ្នកការពារផ្ទះ ប៉ុន្តែការបាត់ខ្លួនចុងក្រោយនេះគ្មានអ្នកណាដែលថាមិនខ្វល់ចិត្តទេ។

ផានូនៅតែបន្តនិយាយបន្ថែមទាំងទឹកមុខហាក់មិនស្ងប់ចិត្ត៖

«ប៉ាម៉ាក់គេអស់នោះដេកលើលុយ! គេប្រកាសចាយដល់ទៅ៥០០លានរៀល នៅតែគ្មានដំណឹង! ពេលនេះ នៅតែមិនទាន់បានកូនស្រីអស់ទាំងនោះត្រឡប់មកវិញផងទេអមរាជា!»

កូនទោលរបស់លោក សាម៉ុន រឹតតែស្តាប់ ចិត្តរឹតតែអស់ត្រេកត្រអាល ទោះយ៉ាងណាដើម្បីបញ្ចប់បរិយាកាសនេះ គេចាប់ផ្តើមបដិសេធយោបល់មិត្ត ហើយកម្លាចិត្តខ្លួនឯង៖

«មិនដឹងគេមានរឿងអីផង! គេមិនមែនបាត់ទៅដោយសារទៅសមោសរព្រះចន្ទឯណាហ្អី?»

ផានូមិនតបត អមរាជារឹតតែបានចិត្តបង្វែរបរិយាកាស៖

«នែ! ឯងគិតមើល ស្រីៗទាំងហ្នឹងអាចថាត្រូវប៉ាម៉ាក់គាបសង្កត់ឲ្យរៀបការរឿងមុខមាត់ត្រកូលអីហ្នឹងបានជាគេខឹងចិត្តបបួលគ្នារត់ចោលផ្ទះអស់ទៅ! មែនអត់ ឯងថាទៅមើលផានូ? ពាក្យចាស់លោកពោលថា មនុស្សយើង បើគេធ្វើជាគេងលក់ យើងដាស់មិនងាយឮទេ ដូចគ្នាឯងគិតទៅមើលពួកនោះពួនលាក់អាត្មាខ្លួនឯងទេដឹង?»

«ឯងមកសួរហ្នឹងគិតថាយើងទ្រង់ញាណហ្មែននាង? មនុស្សកំពុងស្មុគចិត្ត!»

អមរាជាស្រាប់តែញញឹម ហើយលាន់មាត់បែបរីករាយទាំងទះដៃផងតិចៗ៖

«បងឈុនរាជ អាចជួយបានគ្រប់រឿង!»

ផានូធ្វើមុខបែបមិនជឿជាក់ ហើយងាកមកសម្លឹងមិត្តជាថ្មី។ ក្រសៃភ្នែកនាងហាក់ជំនួសសំណួរថា «ទុកចិត្តម្ល៉េះនាង?» គ្រាន់តែស្រីស្អាតមិននិយាយចេញមក ព្រោះចិត្តមួយទៀតនាងក៏កំពុងអន្ទះសាចង់ចេញទៅចូលរួមពិធីដ៏ល្បីគួរឲ្យរំភើបមួយនោះដូចគ្នា។

អមរាជាក្រោកចេញពីបន្ទប់ទុកឲ្យមិត្តរត់តាមត្រឹកៗ៖

«មិនបាច់ទៅរកបងធំឈុនរាជរបស់ឯងទេ! គេមិនឲ្យឯងទៅផង ខាងសមោសរហ្នឹង យើងទៅម្នាក់ឯងមានន័យដែរ? យើងមិនផ្សងព្រេងទេអមរាជា!»

អមរាជាបញ្ឈប់ដំណើរ នាងបែរក្រោយមក ផានូហើយនិយាយខ្សឹបៗ៖

«មិនមែនយើងរកគាត់ឲ្យការពារឯងទៅទេ យើងចង់បកស្បែកអ្នករៀបចំកម្មវិធីនោះ ហើយសួរថា ម៉េចបានគេមិនផ្តល់កិត្តិយសឲ្យយើង?»

ទោះមិត្តនិយាយកំប្លុកកំប្លែង ប៉ុន្តែផានូ បែរជាជិនឆ្អន់។ ស្រីស្អាតពេបមាត់រិះគន់វិញ៖

«ធ្វើដូចបងឈុនរាជផុនឯងហ្នឹង អស្ចារ្យមកពីណាអ៊ីចឹង! តិចត្រូវគេបកស្បែកវិញមិនដឹង?»

វគ្គ សេដ្ឋីក្មេងមហារីន

យុវវ័យដ៏មានភព្វជាមួយសម្បត្តិមហាសាល មានឈ្មោះពិតថា ដារីន ប៉ុន្តែចូលចិត្តឲ្យមនុស្សក្នុងសង្គមហៅខ្លួនថាមហារីន។

ដូចអ្នកមានទូទៅក្នុងលោកនេះ នាយយើងចូលចិត្តត្រេកត្រអាលនឹងកម្មវិធីអស្ចារ្យ ចូលរួមដោយស្រីស្អាត និងវត្ថុមានពួកយុវវ័យក្នុងមជ្ឈដ្ឋានជាន់ខ្ពស់។

គេមានមោទនភាព ចំពោះជោគជ័យរបស់ខ្លួនក្នុងការបង្កើតឡើងនូវកម្មវិធី សមោសរអាថ៌កំបាំង ជាកម្មវិធីដ៏ឆ្នើមកន្ទ្រើងមិនមែនមានលុយសុទ្ធតែបានអញ្ជើញឲ្យចូលរួមនោះទេ។

«ហេតុអី មិនចេញលិខិតអញ្ជើញឲ្យកូនផ្កាយបីម្នាក់នោះ?»

គេសួរទាំងសម្លឹងមេពិធីការស្រី តាមកែវស្រាធំកំប៉ោង ដែលពេញប៊ីបជាតិស្រវឹងក្រហមជៅ។ ស្ត្រីដ៏ស៊ីវិល័យ ក្នុងឈុតស្របខ្លួនតឹងរាវ នៅតែមានរាងកាយស្រឡូនឥតខ្ចោះ ដើរមួយៗមកពីក្រោយថៅហ្វាយ ហើយតបបែបហី៖

«Rose យល់ថាកូនប៉ូលិសកូនអីនាំតែរញ៉េរញ៉ៃដល់សមោសររបស់យើង! ហើយយើងក៏អត់ខ្វះស្រីស្អាតមកចូលរួមឯណា?»

មហាវីននៅស្ងៀមចាំស្ដាប់ តាមទម្លាប់របស់គេ ប៉ុន្តែ Rose ដឹងខ្លួនថាហេតុផលប៉ុននេះម៉េចនឹងអាចទុកថាជាចម្លើយឆ្លើយតបជាមួយបុរសអ្នកមានបាន?

នាងលើកម្រាមពីរដែលលំអដោយក្រចកក្រហមរលោងចិញ្ចែង ទៅត្បៀតកែវសុរាហើយឱនមកទង្គិចជាមួយនាយ មុនពេលនិយាយស្រទន់បង្អួស៖

«មួយរយៈនេះ កូនអ្នកមានបាត់ខ្លួនច្រើនណាស់មហាវីន! ប៉ូលិសកំពុងតាមដានគ្រប់ច្រកល្ហក Roseមិនចង់ឲ្យមានរឿងអីល្អងកករខូចកម្មវិធីយើងទេ!»

គេមិនព្រម Cheer បែរជាក្រោកឡើងពីកៅអី បង្ហាញរាងធាត់កន្ទ្រល ដែលផ្ទុយនឹងទឹកមុខម៉ឹងម៉ាត់របស់គេ។ សញ្ញាមហាវីន គ្មានត្រង់ណាទទួលយកហេតុផលភ័យខ្លាចរបស់ Rose ស្រេចទៅហើយ។ នាយមមីភ្នែកសម្លឹងទៅទិដ្ឋភាពខាងក្រៅនៃរាជធានីពេលរាត្រី តាមរយៈផ្ទាំងបង្អួចកញ្ចក់លាតធំត្រដាង។

«យើងមានពាក់ព័ន្ធស្អី? ខ្លាចអី? ឬមួយយើងចាប់ស្រីៗអស់នោះ?»

គេសួរសង្កត់សំឡេង ហើយបែរមកវិញខ្វាក ធ្វើឲ្យកែវស្រា លើដៃនារីស៊ិចស៊ី សឹងរង្គើទប់មិនចង់ជាប់។

នារីនេះមិនដែលមានពាក្យថា«ខ្លាច»អ្នកណាម្នាក់ នៅគ្រប់ទំព័រនៃជីវិតរបស់ខ្លួនឡើយ ហើយកាលដែលមេពិធីការរបស់ កម្មវិធីសមោសរពន្លឺចន្ទម្នាក់នេះមានរំញោច ក៏ព្រោះតែនាងកំពុងផ្ចង់តាមដានប្រតិកម្មបុរសអ្នកមាន ដែលឈរនៅនឹងមុខម្នាក់នេះយ៉ាងម៉ត់ចត់ជ្រាលជ្រៅ។

Rose មិននិយាយតែការសន្ទនាហាក់បានធូរស្រាលឡើយ។ មហាវីននិយាយបន្ថែមៈ

«កូនស្រីអ្នកមានដែលបាត់ខ្លួន មានខ្លះធ្លាប់បានមកកម្មវិធីយើងផង មុនពេលកើតហេតុ ពេលនេះ ប៉ូលិសបញ្ជូនកូនស្រីគេមក បើយើងមិនទទួលគេដូចជាចង់ប្រាប់គេថាយើងមានខ្លួន? នាងចង់ឲ្យគេយល់ថាយើង ពាក់ព័ន្ធរឿងឧក្រិដ្ឋកម្មចាប់មនុស្សជំរិត?»

«រួចចុះបើគេមកស៊ើបរញ៉េរញ៉ៃខូចកម្មវិធីអ្នកណាទទួលខុសត្រូវ?»

Rose និយាយដោយទឹកមុខស្រទន់ ព្រោះនាងមិនមែនសួរដើម្បីចង់បានចម្លើយ។ សភាពពន្យារពេលពិនិត្យតាមដានរបស់នាង បែរជាធ្វើឲ្យមហាវីនកាន់តែសៅហ្មង។

អ្នកមានផាត់កន្ទ្រល ចង្អុលមុខនារីនេះចំៗគ្មានរអាចិត្តៈ

«កុំឲ្យដឹងឲ្យសោះថាអ្នកណាម្នាក់ក្នុងក្រុមហ៊ុននេះកំពុងលេងល្បិច ពាលស៊ីពាលហើយចង់លាបពណ៌សមោសររបស់ខ្ញុំ!»

នាងដកដង្ហើមវែង សម្រួលអារម្មណ៍ ហើយងាកមុខចេញ ទប់កំហឹងព្រមទាំងសង្កត់សំឡេងៈ

«ប្រាប់មកមហាវីនថាលោកកំពុងសង្ស័យខ្ញុំ!»

មហាវីនទំនងដឹងខ្លួនមកវិញថានាងខឹង។

គេទម្លាក់ចង្អុលដៃចោល បែរក្រោយច្រត់ចង្កេះបញ្ចេញភាពសៅហ្មងៈ

«បើអ៊ីចឹងឆាប់ធ្វើសារអញ្ជើញកូនស្រីប៉ូលិសនោះមក! ធ្វើដូចមិនដឹងរឿង ធ្វើដូចមិនដែលស្គាល់ប្រវត្តិ ធ្វើដូចគ្មានអ្វីកើតឡើងទាំងអស់!»

Rose ដកដង្ហើមយូរជាសញ្ញាថានាងត្រូវបង្ខំចិត្តធ្វើរឿងដែលខ្លួនឯងមិនយល់ស្រប តែគ្មានសិទ្ធិតវ៉ាអ្វី។ ស្រីស្អាតលើកកែវមកអកដាច់ភឹង បង្ខំជាតិស្រវឹងក្នុងរង្វាស់មិនធម្មតា បោលទៅចរាចរណ៍កាត់បំពង់សំឡេងដែលនាងចង់បង្អាក់កុំឲ្យនិយាយពាក្យពិត។

ដង្ហើមនាយមាឌធំនៅតែតឹងតែងបញ្ជាក់ថា ទង្វើរបស់នាងមិនទាន់បានធ្វើឲ្យនាយសប្បាយចិត្តអ្វីឡើងវិញទាំងអស់។ មេពិធីការក្ដាប់មាត់ដើរចេញពីក្រោយខ្នងមហារីន។ នៅនាទីចុងក្រោយ បុរសនេះឆ្លៀតនិយាយបន្ថែម៖

«ពិធីរបស់ខ្ញុំជាពិធីឯកលើលោក! ខ្ញុំដឹង! មានសេដ្ឋីជាច្រើនដែលច្រណែនខ្ញុំដេកមិនលក់! ខ្ញុំដឹងទៀតថាមានលុយមួយចំនួនចូលមកទិញមនុស្សរបស់ខ្ញុំឲ្យធ្វើរឿងរញ៉េរញ៉ៃ បំផ្លាញកម្មវិធីរបស់ខ្ញុំ! ខ្ញុំមិនមាត់ព្រោះវាអត់ប្រយោជន៍! តែលើកនេះវាលេងធ្ងន់ពេកហើយ! ចាប់ភ្ញៀវរបស់ខ្ញុំ ធ្វើឲ្យប៉ូលិសសង្ស័យខ្ញុំ ចង់ឲ្យខ្ញុំបិទសមោសរ???? បើខ្ញុំដឹងថានេះជាទង្វើអាខ្មោចណាមួយ ខ្ញុំនឹងបញ្ជូនវាទៅស្រុកខ្មោចវិញមិនឲ្យក្រោកមករួច!»

សម្ដីច្រឡោងខាមរបស់គេ នាងមិនមែនទើបតែឮដំបូងទេ ចុះហេតុអីមានអារម្មណ៍លើកនេះធ្ងន់ធ្ងរជាងរាល់ដង?

នាងថាដាក់កែវចុះហើយចាកចេញ តែសម្ដីបុរសធាត់ធ្វើឲ្យនាងចេះតែចង់ឈ្នះ។ Rose និយាយទាំងសម្លឹងនាយត្លែះ៖

«គ្រាន់តែហាមកូនស្រីប៉ូលិសម្នាក់តើ! ខ្ញុំគិតសុវត្ថិភាពកម្មវិធីបានខ្ញុំធ្វើអ៊ីចឹង! ឥឡូវឲ្យអញ្ជើញក៏បាន! ចាំបាច់ខឹងរាលដាលទំពីសទំពាសអ៊ីចឹងដែរអត់?»

ថៅកែក្មេងលែងមាត់។

មេពិធីការ នៅឈរស្ដុប ដកដង្ហើមចោលបីបួនសង្វាក់ មុនពេលចាកចេញលឿនរ៉ុយ។

មហារីនដកដង្ហើមយូរ។

គេដឹងថាខ្លួនឯងក៏ជ្រុលបន្តិច យករឿងខ្លីមួយមកនិយាយទៅជាវែងបែកអូរហូរស្ទឹង។ ក៏មិនដឹងខ្លួនឯងដែរថា អារម្មណ៍ឆេវឆាវមួយនេះមកពីគេគិតអំពល់រឿងការបាត់ខ្លួនភ្ញៀវរបស់ខ្លួនមុនៗ ឬក៏បណ្ដាលមកពីគេតានតឹងខ្លាំងពេលដឹងអំពីការលបទាក់ទងគ្នាសម្ងាត់ រវាងមេពិធីការ Rose និងអាណិកជនអ្នកមានស្ដុកដែលទើបមកពីបរទេស។

«Roseចេញពីនេះទៅជួបអាណិកជននោះច្បាស់ណាស់!»

សំឡេងលាន់ចេញមកពីក្រោយវាំងនន។

មហាវីនមិនបែរទៅមើលទេ បានន័យថា គេដឹងពីការលាក់ខ្លួនសំងំស្ដាប់ របស់ម្នាក់ដែលទើបតែបង្ហាញខ្លួននេះ។

គេបញ្ជាខ្សាវៗ៖

«តាមដាន Rose ឲ្យខ្ញុំ!»

បុរសដែលលាក់ខ្លួនម្នាក់នេះអោនកាយធ្វើតាមរហ័សរហួន។ មុនពេលគេចាកចេញ មហាវីនឆ្លៀតបន្ថែម៖

«ខ្ញុំមិនចង់គិតខុសលើមនុស្សរបស់ខ្ញុំទេលេខាដេវីដ! ចង់ឲ្យខ្ញុំជឿថា Rose ក្បត់ទាល់តែមានភស្តុតាងច្បាស់!»

លេខានៅស្ងៀម គ្មានអ្នកណាមើលឃើញកំនួចសម្ងាត់ក្នុងកែវភ្នែករបស់គេឡើយ។

ការប៉ះទង្គិចគ្នារវាងអ្នកក្រោមបង្គាប់ជារឿងធម្មតា ប៉ុន្តែសេដ្ឋីម្នាក់នេះ ត្រូវធ្លាក់ក្នុងស្ថានភាពក្រពុលមុខព្រោះសភាពការណ៍ ហាក់បីដូចកាន់តែគំរាមកំហែងខ្លាំងឡើងពីមួយថ្ងៃទៅមួយថ្ងៃ។

ភាគទី១២

កម្មវិធីរាត្រីសមោសរដ៏ចម្លែកមួយដែលមហាវីនបានខិតខំថ្នៃប្រឌិតបង្កើតឡើងធ្វើយ៉ាងណាឲ្យមានលក្ខណៈពិសេស មានតែមួយគ្មានពីរ មានលក្ខណៈមហស្ចារ្យ ល្បីឆ្ងាយតែពិបាកចូលដល់ មិនប្រាកដថាមានប្រាក់អាចមកឃើញបាន ពេលនេះកំពុងត្រូវបានបុរសអ្នកមានចាត់ថាជាដើមចមនៃការព្យាបាទ។

គេយល់ថា ខ្លួនកំពុងដំណើរការអ្វីៗប្រកបដោយជោគជ័យណាស់ ចំណែកឯការបង្កើតឲ្យមានករណីបាត់ខ្លួនជាបន្តបន្ទាប់ទាំងនេះ បើមិនជាអន្ទាក់តើជាអ្វីវិញ?

ប្រសិនបើប៉ូលិសចាត់ទុកថាកម្មវិធីនេះនិងការបាត់ខ្លួនបណ្ដាកូនស្រីអ្នកមានកាលពីពេលថ្មីៗពិតជាមានការពាក់ព័ន្ធគ្នា គ្រប់យ៉ាងមិនក្លាយជាលទ្ធផលគួរឲ្យសោកស្ដាយបំផុតហើយ។

អ្នកមានវ័យក្មេងឈ្មោកចាក់បន្ថែមសុរាដោយចិត្តសៅហ្មង ក៏ជាឱកាសឲ្យលេខាឈ្មោះដេវីដថែមក្រមួនប្រេងម្សៅលើស្ថានការណ៍មិនឈប់ឈរទៀត ៖

«ថៅកែវីនគិតមើល៍! អ្នកណាម្នាក់ដូចជាកំពុងមានផែនការលេងយើង! មនុស្សបាត់៥នាក់ សុទ្ធតែមុន ឬក្រោយបានចូលរួមកម្មវិធីយើង! ទោះបីអ្នកចូលសមោសរពណ៌ព្រះចន្ទ សុទ្ធតែចូលជាសម្ងាត់ តែពេលនេះ កូនអ្នកមានអស់ហ្នឹងនៅសុខៗបាត់ខ្លួន ប៉ូលិសចាប់ផ្ដើមស៊ើបល្អិតគ្រប់រឿង គ្រប់សកម្មភាព! មុនក្រោយប៉ូលិសគង់តែដឹង ហើយគេគង់តែមកដល់កន្លែងយើង!»

គេក្ដាប់ដបស្រាណែន ភ្នែកសម្លក់ជាតិស្រវឹង ហើយបង្អង់ទ្រឹង ធ្វើឲ្យលេខាឈ្មោះដេវីដ ញញឹមព្រោះបានដូចចិត្ត។

ដឹងអីស្រាប់តែសេដ្ឋីក្មេងងាកមកវិញហើយនិយាយសង្កត់ពាក្យតប៖

«តែបើឲ្យខ្ញុំមានគំនិតសង្ស័យ Rose ខ្ញុំគ្មានភាគរយច្រើនទេ! Rose គេជាមនុស្សត្រង់ទៅត្រង់មក គេពូកែ តែគេអត់ល្បិចទេ! ខ្ញុំស្គាល់គេច្បាស់ ខ្ញុំដឹងចរិតគេ!»

«តែថៅកែមិនដឹងទេថា លុយប៉ុន្មានអាចធ្វើឲ្យទស្សនៈគេដូរបាន!»

លេខានិយាយមិនខ្លាចកំហឹងដែលកំពុងលឺបលល្អួចលាក់ក្នុងទ្រូងបុរសរាងធាត់នេះ។ គេឃើញមហាវីនលុះជាមួយពាក្យបញ្ឆោះ ងាកទៅសម្លក់ទេសភាពខាងក្រៅ។ អ្វីៗហាក់បីដូចជាសញ្ញាទុកពេលឲ្យខាងលេខា អាចបានឱកាសលើកហេតុផលមកបន្ថែមមិនចេះទញ់ទាល់៖

«Lorenzo មានបំណងស្អីក៏មិនដឹង តែគេមានណាស់ មានដល់ថ្នាក់វាស់មិនដឹងថាគេបានលុយមកពីណា ហើយឥឡូវនេះ គេមកកម្ពុជាលឺបលចុះឡើង តើគេចង់បានអី?»

មហាវីនញាក់ស្មាចំអកឲ្យអ្វីដែលខ្លួនឯងកំពុងស្ដាប់ឮ វាមិនខុសអ្វីពីកាយវិការអ្នកមាននានានៅរាល់ពេលឮថាមានអ្នកណាម្នាក់កំពុងត្រូវបានគេសរសើរថា ស្ដុកស្ដម្ភ កប់ក្ដោង ជាងខ្លួននោះទេ។

លេខាដេវីដ ដឹងចំណុចខ្សោយនេះ បានជាពាក្យស៊កសៀតរបស់គេ មានក្បួនរលូនឥតទាស់ឥតទាក់ ហើយក៏មិនទើរ។

សំឡេងគេពុះជ្រែកបេះដូងលោតញាប់របស់ម្ចាស់សមោសរអាថ៌កំបាំង៖

«ខ្ញុំសង្ស័យ តាំងពីពេលដែលគេ មកជួបយើង ដាក់ពាក្យជាភ្ញៀវប្រចាំគ្រប់កម្មវិធីពណ៌ព្រះចន្ទ! គេនោះប្រាកដណាស់ គេមានបំណងអ្វីមួយ ហើយចុងក្រោយ គេលបទាក់ទងគ្នាយើង! ហើយគ្នាយើងបានព្រមចូលជាមួយគេជាសម្ងាត់!»

ឃើញថៅកែនៅស្ងៀមលែងមាត់ ដេវីដនិយាយថែម៖

«Rose មិនព្រមឲ្យកូនស្រីផ្កាយបី ឌិត សាម៉ុន មកចូលរួមកម្មវិធីយើង នាងមានចេតនាឲ្យប៉ូលិសបាញ់ទិសដៅមករកយើងច្បាស់ណាស់! ថាមិនបាន នាងរួមដៃជាមួយអាអាណិកជនម្នាក់ហ្នឹង បង្កើតរឿងពង្រត់កូនស្រីអ្នកមានហើយទាញយើងឲ្យចូលស៊ង!»

មហាវីនពុះពោរទ្រូង តែនាយខំរក្សាវាតែម្នាក់ឯង ដោយនិយាយខ្លីៗបញ្ឈប់បទវិភាគវែងអន្លាយនេះ៖

«បើគ្មានភស្តុតាង ឈប់និយាយពាក្យអត់ប្រយោជន៍!»

ដេវីដជ្រប់មុខពេលត្រូវថៅកែបែរមកចំ។

«ឮអត់? ទៅរកភស្តុតាងមក!»

សម្ដីមហាវីនលាន់មកច្បាស់ៗ ហាក់បីដូចជាខំព្យាយាមបិទបាំងចិត្តញាប់ញ័ររបស់ខ្លួនឯង៖

«ហើយមួយទៀត! បើតាមដាន តាមដានទាំងពីរ!»

ដាវីដងើបមុខមកជាថ្មី ធ្វើឲ្យថៅកែក្មេងបន្ថែមសម្ដី៖

«ទាំង Rose ទាំងអាម្នាក់ Lorenzo ស្អីគេហ្នឹង!»

ដេវីដឱនលំទោនជាមួយកន្ទុយភ្នែករេចុះឡើង។

បុគ្គលនេះមានចេតនាប្រឆាំងជាមួយ Rose ករណីនេះមិនមែនមហាវីនជាមេកោយមិនដឹងអ្វីនោះទេ។ ចិត្តគេក៏បែរបន់ឲ្យ Rose កុំដូចអ្វីដែលដេវីដបានលើកឡើងដែរ តែក្នុងស្ថានភាពនេះ មិនតាមដានដឹងខុសត្រូវខ្មៅស ម៉េចនឹងនៅសុខ?

មហាវីនសម្លឹងដំណើរចាកចេញរបស់លេខាប្រុស មុនពេលដែលនៅសល់តែម្នាក់ឯងក្នុងបន្ទប់កញ្ចក់។

«កុំឲ្យអញដឹងឲ្យសោះវ៉ឺ!»

គេរអ៊ូម្នាក់ឯងស្ងាត់ៗ...

វគ្គ អាណិកជនមានកប់ពពក Lorenzo

ប្រសិនបើ Rose ចង់រួចខ្លួន នាងមិនគួរមានការពាក់ព័ន្ធជាមួយមនុស្សគួរឲ្យសង្ស័យណាម្នាក់នៅក្នុងដំណាក់កាលនេះទេ ។ មានតែនាងប៉ុណ្ណោះដែលដឹងថាអ្វីជាអ្វី ហើយច្បាស់ពីអ្វីដែលខ្លួនឯងកំពុងតែប្រឈម។

«ខ្ញុំមិនដែលសង្ស័យមហាវីនទេ តែពេលនេះ ខ្ញុំយល់ថាគេដូចជាមានអ្វីមួយមិនប្រក្រតី!»

ស្រីស្អាតឆើតនិយាយទាំងចិត្តខ្វល់ខ្វាយ។

បុរសដែលអង្គុយស្តាប់មិនមានប្រតិកម្មអ្វីច្រើន ក្រៅតែពីគោះម្រាមដៃរបស់គេលើផ្ទាក់កៅអីប៉ូកៗចុះឡើង។ សភាពតក់ក្រហល់របស់នាងធ្វើឲ្យគេដឹងជាស្រេចថា នារីនេះកំពុងតែស្ថិតនៅក្នុងសភាពមិនច្បាស់លាស់ទាំងខ្លួនឯងផង។

គូសន្ទនាមិនតបតដូចទុកពេលឲ្យនាងនៅតែនិយាយចុះឡើងមិនឈប់៖

«មហាវីនដូចជាឆ្កួន គេដឹងថាក្មេងស្រីនោះជាកូនមេប៉ូលិស គេនៅតែចចេសគឃ្លើនចង់ឲ្យនាងមកចូលរួម!»

«ស្រីម្នាក់នោះស្អាតអត់?»

សំណួរខ្លីនេះលេចចេញពីបបូរមាត់បុរសដែលក្រនឹងនិយាយ។ ទោះបីអត្ថន័យវាខ្លីប៉ុន្តែអាចធ្វើឲ្យ Roseធ្លាក់ទឹកចិត្តរហូតដល់ថ្លោះទាំងទឹកមុខ។

នារីស៊ីវិល័យនេះក្រពាត់ដៃនិយាយបន្ទាប់ពីបង្អង់ប៉ុន្មានវិនាទីតែប៉ុណ្ណោះ៖

«Loren គិតថាប្រុសៗគ្រប់គ្នាសុទ្ធតែឆ្កួតនឹងពួកស្រីស្អាតៗ រួមទាំងមហាវីនផងហ្អី?»

Lorenzo ញញឹមតិចតួច។ ទោះប៉ុណ្ណឹងក៏ល្មមឲ្យនារីម្នាក់នេះឆ្កួតចិត្តនឹងភាពស្រស់សង្ហាររបស់នាយទៅទៅហើយ។

នាងក្រពាត់ដៃធ្វើតោះតើយហាក់ប្រចៃប្រចណ្ឌ។

មានអារម្មណ៍ដឹងមុនថានារីណាម្នាក់កំពុងលង់គេ វាគឺជាជំនាញរបស់បុរសគ្រប់គ្នា ហើយដែលអាណិកជនធ្វើមិនដឹងរហូតមកនេះ ក៏ព្រោះតែគេទំនងជាគ្មាននាងក្នុងបេះដូងអ្វីបន្តិចឡើយ។

Lorenzoដឹងថានាងធ្វើចរិតហាក់ចង់បង្ហាញភាសាសម្ងាត់ថា «លោកដឹងទេ ថាសម្ដីលោកកំពុងបញ្ឈឺខ្ញុំ?»។

រោមភ្នែកទាំងសងនៃនារីឆើតឆាយបាញ់ឆ្ពោះទៅរកបុរសខ្មែរប្រើឈ្មោះបរទេសម្នាក់នេះ។

«ស្រីៗជាច្រើនចង់ឃើញលោកបានជាគេមកសមោសរ!»

សម្ដីនាងបណ្ដាលឲ្យគេបែរមកយឺតៗ មកជាមួយភាពសោមនស្សបង្កប់ជ្រៅក្នុងកែវភ្នែក។ គេមិន ញញឹម តែភាពស្មើធេងលើផ្ទៃមុខរឹតតែបង្កើនថាមពលបុរសភេទលើរាងកាយគេ គួរឲ្យទាក់ទាញចិត្ត។

អ្នកមានដ៏អាថ៌កំបាំងម្នាក់នេះហាក់កំពុងពេញដោយសេចក្ដីមោទនភាព។ នាងក្នាញ់នឹងភាពព្រងើយក្រអឺតរបស់គេណាស់ដែរ ប៉ុន្តែកាត់ចិត្តថាស្អប់គេមិនបាន។

សំឡេងគេលាន់មក៖

«តែមហាវីន មិនចូលចិត្តខ្ញុំទេ មិនអ៊ីចឹង?»

Rose ដកដង្ហើមធំដែលពង្វាងស្ថានការណ៍បានល្អហើយលឿនទៀត។ នាងនៅស្ងៀមព្រោះមិនដាច់ចិត្តនិយាយការពិតណាមួយចេញមកនាំឲ្យប៉ះពាល់ដល់បុរសទាំងពីរ។ ទោះបីយ៉ាងណា Rose មិនសមថាមើលស្រាលបុរសនេះ ទុកដូចគេមិនដឹងរឿងអ្វីទាំងអស់នោះទេ។

គេនិយាយតិចៗពេលដែលមិនឮចម្លើយ៖

«ពេលនេះគេសង្ស័យនាងហើយដឹង?»

នាងងើបមុខសម្លឹង Lorenzo យឺតៗ។ គេញាក់មុខឲ្យនាងសម្លឹងទៅពិតានដែលនៅទីនោះអេក្រង់ទូរទស្សន៍ធំមួយកំពុងផ្ដោតលើរថយន្តបោលចុះឡើង។

ដៃនាយចុចទាញរូបភាពឲ្យសារចុះសារឡើង ហើយពង្រីកកាន់តែធំ។

«ដេវីដ?»

Rose របូតមាត់រអ៊ូ ព្រោះមិនជឿថាពេលនាងចូលមកភូមិគ្រឹះនេះ បុរសលេខាមកទាន់ពីក្រោយស្ងាត់ៗ តាមដាននាងស្អិតដូចស្អករ?

នាងលើកដៃម្ខាងចង្អុលអេក្រង់ ហើយកែវភ្នែកបាញ់មកសួរបុរសនេះក្នុងកាយវិការជំនួសសំណួរថា៖

«អាម្សៀហ្នឹងតាមដានខ្ញុំ?»

Loren ញាក់ស្មាតាមបែបអឺរ៉ុប។ គេមិនឆ្លើយគឺមានន័យថា នាងគិតខ្លួនឯងមើលទៅ។ សំឡេងមហាវីនរំឭកមកវិញក្នុងការចងចាំ «កុំឲ្យដឹងឲ្យសោះថា អ្នកណាម្នាក់ក្នុងក្រុមហ៊ុននេះកំពុងលេងល្បិចពាលស៊ីពាល ហើយចង់លាបពណ៌សមោសររបស់ខ្ញុំ!»

ស្រីស្រស់ក្តាប់មាត់សៅហ្មងចិត្ត។ នាងនិយាយ៖

«ខ្ញុំប្រដៅអាលេខាម្នាក់ហ្នឹងម្តង!»

ប្រុសស្អាតសើចបញ្ចេញសំឡេងតិចៗ ជាហេតុឲ្យ Rose បោះបង់ចោលគំនិតដែលថាចង់ចេញទៅក្រៅនោះភ្លាម។ បើមិនបានសួរគេ នាងមិនចេញទៅកើតទេ នាងជះសម្តីខ្លី៖

«Loren សើចអី?»

មិនមានចម្លើយមានតែសំណួរបកក្រោយមកវិញ៖

«គេគិតថានាងកំពុងក្បត់គេ ហើយធ្វើអ្វីម្យ៉ាងឲ្យខ្ញុំប្រឆាំងនឹងគេ?»

នាងមួម៉ៅចិត្តពេលឮគូសន្ទនារំឭករឿងនេះ។ ស្រីស្រស់តបតវិញជាមួយសំណួរមិនគួរឲ្យចង់ស្តាប់៖

«ខ្ញុំគ្រាន់តែខ្លាចស្រីម្នាក់កូនផ្កាយបីនោះបំផ្លាញកម្មវិធីសមោសរ ក្រៅពីហ្នឹងខ្ញុំអត់ខ្វល់អីទាំងអស់! ដឹងអីគេស្រាប់តែហៅខ្ញុំមកសួរនាំថាហេតុអីហាមក្មេងនោះ? គេមិនស្តាប់ហេតុផលហើយ ស្រាប់តែខឹងក្រពុលមុខនិយាយដៀមដាមចុះឡើង ដូចជាមានអ្នកណាម្នាក់កំពុងដែលលាក់កាំបិតចាក់គេអ៊ីចឹង!»

«ចុះនាងមានបានធ្វើអត់?»

Rose ចងចិញ្ចើមពេលឮសំណួរស្រាលៗក្នុងសំឡេងថ្នមៗរបស់គេ។ បើគេពុំមែនជាបុរសដែលនាងមានចិត្តឲ្យ កុំអីនាងមិននៅទីនេះខាតពេលប្រដៅនាយដេរីដទេ។ ស្រីស្រស់និយាយញ៉ែតៗ៖

«លោកឃើញហើយ Loren! រវាងយើងគឺមិត្ត ខ្ញុំមិនបានធ្វើអីបំផ្លាញមហាវីនទេ! ខ្ញុំមកជួបលោកព្រោះយើងរាប់អានគ្នា ហើយលោកថាទុកខ្ញុំជាមិត្តម្នាក់! អូៗៗ តិចលោ មហាវីនក្រពុលមុខរៀងបាត់ខ្លួនស្រីៗហ្នឹង ហើយស្មានផ្តេសផ្តាសថាខ្ញុំចូលដៃជាមួយលោកបំផ្លាញកម្មវិធីគេ? យ៉ាប់មែនហើយ!»

«ចុះនាងមានធ្វើអត់?»

គេនេះសួរដដែលៗទៀត? នាងងាកមុខមកមើលមុខបុរសអាណិកជនជាសញ្ញាព្រមានថានាងធុញនឹងភាសាច្រំដែលនេះ ពេកហើយ។

Lorenzo នៅតែមិនញិន។ នាយលើកចិញ្ចើមនិយាយបន្ថែម៖

«បើមិនមែនបានធ្វើអីខុស ចាំបាច់អីទៅកើតទុក្ខខ្វល់ថាអ្នកណាតាមដាន! ផ្ទះនេះអត់ខ្លាចអ្នកណាមកតាមដានជិះក្រឡឹងចុះឡើងសឹកផ្លូវទេ ធ្វើម៉េចធ្វើទៅ កុំឲ្យតែចូលដល់របងផ្ទះខ្ញុំ!»

បុរសនេះនិយាយចប់កាលណា ក៏នាំរាងកាយខ្ពស់ស្រលះដូចកូនអាមេរិកាំងដើរទៅក្បែរបង្អួចហើយទាញបិទវាំងននខ្វាក។ ដំណើរគេដែលមើលពីក្រោយជាមនុស្សឆ្លាតវាងវៃ ធ្វើឲ្យនាងនឹករឮកទៅដល់សម្តីរបស់មហាវីន « ខ្ញុំដឹងទៀតថា អ្នកមានលុយមួយចំនួន ចូលមកទិញមនុស្សរបស់ខ្ញុំ ឲ្យធ្វើរឿងរញ៉េរញ៉ៃ បំផ្លាញកម្មវិធីរបស់ខ្ញុំ! ខ្ញុំមិនមាត់ព្រោះវាអត់ប្រយោជន៍! តែលើកនេះវាលេងធ្ងន់ពេកហើយ! ចាប់ភ្ញៀវរបស់ខ្ញុំ ធ្វើឲ្យប៉ូលិសសង្ស័យខ្ញុំ ចង់ឲ្យខ្ញុំបិទសមោសរ??? បើខ្ញុំដឹងថានេះជាទង្វើអាខ្មោចណាមួយ ខ្ញុំនឹងបញ្ជូនវាទៅស្រុកខ្មោចវិញមិនឲ្យក្រោកមករួច!»

អ្វីដែលនាងកំពុងផ្តោតគិតសំខាន់ក្នុងពេលនេះគឺថា ហេតុអ្វីបានជាមហាវីន ប្រើលេខាតាមនាងដល់ទីនេះ មានតែគេយល់ថាបុរសអ្នកមានម្នាក់នេះកំពុងជែងអ្វីម្យ៉ាងជាមួយគេ? «ពិធីរបស់ខ្ញុំ ជាពិធីឯកលើលោក! ខ្ញុំដឹង! មានសេដ្ឋីជាច្រើនដែលច្រណែនខ្ញុំដេកមិនលក់!»

នឹកដល់សម្ដីចៅហ្វាយនាយត្រង់ចំណុចនេះ នារីរវេភ្នែកទៅរក Lorenzo។ គេសុខៗមកដល់កម្ពុជាហើយធ្វើជាភ្ញៀវប្រចាំរបស់សមោសរពណ៌ព្រះចន្ទ? តើអ្នកណាមិនសង្ស័យគេ?ពេលនេះ គេមានអារម្មណ៍បែបណាដែលព័ត៌មានបាត់ខ្លួននារីៗអស់នោះ លាន់ឮគ្រប់មជ្ឈដ្ឋានទៅហើយ។

«Loren! លោកដឹងរឿងស្រីៗបាត់ខ្លួនអស់ទាំងហ្នឹងអត់?»

Lorenzo តបវាំហ៊ី៖

«រឿងណាមិនទាក់ទងជាមួយខ្ញុំ ខ្ញុំមិនចង់ដឹងទេ!»

តែ Rose សង្កេតឃើញគំនិតដ៏ជ្រៅមួយបង្កប់ក្នុងកែវភ្នែកប្រុសស្អាតម្នាក់នេះ។

«សម្ដីមហាវីន ក៏ពុំមែនខុសទាំងអស់ដែរ! អាចទេ? អ្នកណាម្នាក់ពិតជាកំពុងមានគម្រោងចង់បំផ្លាញសមោសរ ពណ៌ព្រះចន្ទ ព្រោះមិនចង់ឃើញមហាវីនជោគជ័យ?»

នាងសួរទាំងតាមដានចរិតបុរសនេះមិនប្រិចភ្នែក។

នាងកំពុងរង់ចាំប្រតិកម្មរបស់គេ ប៉ុន្តែគេធ្វើហី មិនញញឹមមិនទោមនស្សក៏មិនឆ្លើយ។

នាងថាបន្តមួយៗ៖

«Loren សុខៗបង្ហាញខ្លួនជាមួយភាពមហាសាល! ចេញចែកអំណោយគ្រប់ទិសទី លាក់មុខតែល្បីឈ្មោះ! លោកបបង្ហាញខ្លួនក្នុងសមោសរពណ៌ព្រះចន្ទជាភ្ញៀវពិសេស ហើយចុងក្រោយករណីចាប់ស្រីៗកក្រើក ក្រុងភ្នំពេញ មកឆ្លើយថាមិនខ្វល់ព្រោះមិនមែនរឿងខ្លួន?»

នៅតែគ្មានចម្លើយ រហូតដល់នាងដកដង្ហើមធំនិយាយបន្ថែម៖

«ទោះមានអំនួត មានជំនឿចិត្តប៉ុនណាក៏លោកត្រូវប្រយ័ត្នខ្លួនដែរ!»

នាងបម្រុងដើរចេញ ចិត្តមួយនឹកគេ ចិត្តមួយស្អប់ភាពឡូយឆាយ និងអស្មិមានះលើកខ្លួនឯងដាក់លើចង្កេររបស់គេ ប៉ុន្តែសំខាន់នាងនៅតែចង់បន្តទូន្មានគេ៖

«ជួនកាល អំនួតរបស់លោក នឹងធ្វើបាបលោក Loren!»

សំឡេងបុរសនេះលាន់មកមួយៗពីក្រោយខ្នងនាង៖

«ផ្តាំចៅហ្វាយកន្ទាត់របស់នាងផងRose! ប្រណាំងជាមួយខ្ញុំមិនចាំបាច់ប្រឌិតរឿងអស់ហ្នឹងឡើងមកទេ!»

Lorenzoពិតជាគិតថា ការបាត់ខ្លួនស្រីៗជាចំណែករបស់មហាវីន???

Rose នៅទ្រឹងមាត់ទ្វារបន្តិច មុនពេលតបៈ

«អ្នកទាំងពីរធ្វើឱ្យខ្ញុំឈឺក្បាលពេកហើយ!»

វគ្គ ចំណាត់ការបងឈុនរាជ

នេះជាពេលវេលាដែលនារីទាំងទ្វេមករកជំនួយការ ឲ្យសម្រេចចិត្តរឿងគួរ ឬមិនគួរទៅចូលរួមពិធីសមោសរពណ៌ព្រះចន្ទ។ ដូចរាល់ដង បងធំមាឌល្មិតតែងតែត្រេកត្រអាលជាមួយទឹកដោះគោកំប៉ុង។

ផានូរអ៊ីរង្ស៊ីវៈ

«បងឈុនរាជជួយគិតមើល! ឲ្យខ្ញុំទៅចូលរួមម៉េចកើត បើចេញស៊ីលមក ឲ្យទៅតែម្នាក់! ហើយអមរាដាកូនប៉ូលិសស្រាប់ តែគេមិនឲ្យទៅ?»

ឈុនរាជលែងកំប៉ុងភេសជ្ជៈមក ហើយចាប់ផ្តើមងក់ក្បាលផ្ងក់ៗ ទទួលស្គាល់ថាហេតុការណ៍ហាក់មិនប្រក្រតី។ គេដឹងថានារីនេះនៅតែមានបំណងមុតស្រួចក្នុងការទៅរកស្គាល់ទេវបុត្រសប្បុរស តែចិត្តមួយនៅមិនសុខគេងមិនលក់បក់មិនល្ហើយរឿងសុវត្ថិភាព។

អាកប្បកិរិយាបងឈុនរាជតែងតែគេកាន់តែឲ្យនិស្សិតទាំងពីរមានទំនុកចិត្តក្នុងការពិភាក្សាជាមួយជាងមុនទៅទៀត។

មនុស្សបង្កប់របស់ប៉ូលិសរូបនេះឆ្លៀតឱកាសទាញត្រីឲ្យឃើញនុយៈ

«ម៉ោះៗៗ អង្គុយចុះប្រាប់បងតាមសម្រួល! ដំបូងបងចង់ដឹងគ្រប់យ៉ាង! គឺគ្រប់យ៉ាងទាំងអស់ទាក់ទងនឹងកម្មវិធីអីពណ៌ព្រះខែស្អីគេហ្នឹង!»

«គឺពណ៌ព្រះចន្ទណាបង!»

អមរាដានិយាយទាំងអង្គុយចុះយឺតៗក្បែរផានូ។

នាងបន្ថែមនៅពេលផានូកំពុងតែនៅមិនសុខមិនសាប់៖

«ដែលខ្ញុំមិនយល់គឺនៅពេលដាក់ពាក្យទៅទាំងអស់គ្នា ស្រាប់តែមកហៅទៅតែម្នាក់!»

«ចុម! សុទ្ធតែដាក់ពាក្យ?»

ការសួរធ្វើពើជាជំនាញរបស់ប្រធាននិស្សិតមាឌល្អិតម្នាក់នេះ ទោះបីជាគ្រប់យ៉ាងទាក់ទងនឹងសមោសរពណ៌ព្រះចន្ទត្រូវបានមេប៉ូលិសពន្យល់ហើយរួចរាល់ក្តី។ សូម្បីតែឈ្មោះកម្មវិធីក៏ឈុនរាជធ្វើជាមិនស្គាល់ច្បាស់ ហៅមិនត្រូវផង រឿងអីដែលថានារីទាំងពីរអាចកើតគំនិតសង្ស័យលើអ្នកប្រឹក្សាម្នាក់នេះកើត?

ផានូចាប់ផ្តើមរៀបរាប់...

នៅឯណេះឧត្តមសេនីយ៍ ឱត សាម៉ុន ទទួលបានសាររបស់នាយបង្កប់...

«កូនស្រីពូនិងផានូចេញទៅវិញបាត់ហើយ! ខ្ញុំក៏ដឹងអស់ដែរពីរឿងគ្រប់យ៉ាងជុំវិញដំណើរការចូលរួមសមោសរពណ៌ព្រះចន្ទ! គ្រប់គ្នាត្រូវចុះឈ្មោះ ផ្ញើរូបថត ហើយសមាសភាពគ្រួសារ! កម្មវិធីប្រព្រឹត្តិទៅបានច្រើនដងហើយ ធ្វើនៅកន្លែងខុសគ្នា មិនប្រាប់មុនមានតែអ្នកដែលត្រូវបានគេអនុញ្ញាតឲ្យចូលរួមទើបអាចមានលេខសម្ងាត់និងដឹងទីតាំងពេលវេលា!»

លោក ឱត សាម៉ុន ឆាតបន្ថែមទៅរកប្រធាននិស្សិត។

រយៈពេលកន្លងទៅប្រមាណ១០នាទី គាត់ងាកមករកឯកមានដែលកំពុងបើកកុំព្យូទ័រស្រាប់និងមានវត្តមានក្បែរកាយ។

«ផានូ យល់ព្រមឲ្យឈុនរាជ រក្សាទុកទូរស័ព្ទ ពិនិត្យ រកបណ្តាញ!»

ឯកមានញញឹម តបវិញ៖

«ខ្ញុំចេញទៅរកបងធំល្អិតម្នាក់ហ្នឹងភ្លាម!»

ឧត្តមសេនីយ៍ងក់ក្បាលផ្ងក់ៗយល់ស្រប ឲ្យនាយ Hacker ចេញទៅយកទូរសព្ទមកឆែករកប្រភព។ នៅសល់តែចិត្រា ដែលកំពុងធ្វើការជាមួយសំណុំរឿងមួយគំនរធំលើតុសាឡុង។

«ឈុនរាជបានឲ្យយោបល់ឲ្យអមរាដានិយាយរឿងលម្អិតជុំវិញសមោសររអាថ៌កំបាំងប្រាប់ប៉ូលិស!»

ចិត្រាលើកចិញ្ចើម ហាក់ឆ្ងល់ធ្វើឲ្យគាត់ញញឹមនិយាយបន្ថែមៈ

«គឺនិយាយប្រាប់ខ្ញុំនឹងហើយ!»

ចិត្រាញញឹមតបៈ

«មធ្យោបាយបំភ័យរបស់លោកនាយមានប្រសិទ្ធភាពណាស់ទាន!»

ភាគទី១៣

នៅឯណោះ Rose វិលមករកមហាវីន។

នៅប្រែបមាត់ទ្វារ នាងឃើញស្រមោលលេខាដេវីដ នាងដឹងថា គេនិយាយជាមួយមហាវីនរឿងដែលទាក់ទងនឹងខ្លួនច្បាស់ណាស់។

Rose រុញទ្វារចូលទៅទាំងទទឹងទទែង បង្ហាញថានាងមានរឿងត្រូវជម្រះបញ្ជីជាមួយនិងអ្នករណប អុចអាលម្នាក់នោះ...

មហាវីនចំហមាត់ពេលមេពិធីការបង្ហាញវត្តមានគ្មានសុជីវធម៌ ហើយហាក់ពុំមែនជាចរិតការងាររបស់ Rose ធ្លាប់មានពីមុនមក...

លេខាដេវីដថយទៅម្ខាង ធ្វើហាក់ទន់ភ្លន់ឱនលំទោន ទោះបីជាក្នុងចិត្តខ្លួនឯងដឹងថាភ្នំភ្លើងកំពុងហៀរមកនូវចំហាយក្តៅ។

មហាវីនវិញ នាយក៏ដឹងចរិតត្រង់ទៅត្រង់មករបស់មនុស្សស្រីម្នាក់នេះ។ ម្ចាស់សមោសរចម្លែក ដឹងថានាង Rose ពេលនេះមិនមែនមកដោយខ្លាចរណបទេ។

បុរសធាត់គ្រហែមសម្រួលសំឡេងមុនពេលបន្ទោសតិចៗៈ

«អត់ចេះគោះទ្វាទេ?»

ជាមេពិធីការដែលមានចរិតលក្ខណៈទទួលឥទ្ធិពលពីលោកខាងលិច Rose និយាយដោយទឹកមុខឌឺដងៈ

«ចង់មកឲ្យទាន់ពួកអ្នកធ្វើការក្រោយខ្នងគេ ទាល់តែមិនចាំបាច់ឲ្យសញ្ញាមុន!»

មហាវីនងៀងភ្នែកទៅរកលេខា ហើយមាត់រកពាក្យដោះសារយឺតៗ៖

«និយាយពីស្អីហ្នឹង Rose?»

Rose ដាក់ភ្នែកចេញពីមហាវីនហើយងៀងទៅរកដេវីដ។ នាងដាក់សំណួរមួយៗ៖

«លោកឯងតាមដានខ្ញុំពីក្រោយ មានបំណងស្អី?»

មហាវីនដឹងថា ដេវីដបែកការណ៍។ គេក្រពាត់ដៃការពារកូនចៅ៖

«កន្លែងនេះ មិនមែនសម្រាប់ឈ្លោះគ្នាទេ!»

«អ៊ីចឹងមានតែមហាវីននៅពីក្រោយការងារអន់របស់ម្នាក់នេះ!»

សម្ដី Rose គឺគ្រោតគ្រាតអ៊ីចឹងហើយពេលនាងខឹង។ បើមិនអ៊ីចឹង មហាវីនក៏មិនចាំបាច់សង្កត់ចិត្តដែរ។ គេបែរមករកនាងហើយទទួលស្គាល់៖

«ត្រូវ! លេខាធ្វើអី បើចៅហ្វាយមិនប្រើ គេម៉េចហ៊ាន?»

Rose នៅតែមិនព្រមអន់។ នាងញាក់ចិញ្ចើមផ្ដើនបុរសធាត់ហើយតបត៖

«មហាវីនសង្ស័យខ្ញុំ? តាមដានខ្ញុំ ស្មានថាខ្ញុំមកធ្វើការនៅទីនេះសម្រាប់ឲ្យគេគ្រប់គ្នាត្រួតពិនិត្យទាំងការងារ personal របស់ខ្ញុំទៀត?»

ស្ថានភាពនាងគឺខឹងដល់កម្រិត ហើយអាកប្បកិរិយានាងដូចបញ្ជាក់ប្រាប់បុរសនេះជាស្រេចថា នាងត្រៀមក្នុងការចប់ជាមួយគេ។

គេក្ដៅចិត្តហើយនិយាយផ្ទួង៖

«អ៊ីចឹងយើងលបលួចជួបអាអាណិកជននោះធ្វើអី?»

Rose ក្រពាត់ដៃ នាងនិយាយជាមួយបបូរមាត់ក្រហមទុំនោះ ដោយមិនចាំបាច់បង្អង់រកនឹកពាក្យតប៖

«ពាក្យលបជួបមានន័យថាម៉េច? បើខ្ញុំលបជួបគេមែន ខ្ញុំព្រមឲ្យលេខាសំគិសរបស់មហាវីនទៅឃើញពីរនាក់ខ្ញុំងាយៗអ៊ីចឹងដែរអត់?»

មហាវីនត្រូវនៅស្ងៀមព្រោះរកពាក្យឆ្លើយមិនបាន។ ចំណែកសម្តីរបស់នាងធ្ងន់ឡើងៗ ធ្វើឲ្យដេវីដត្រូវតែតបតវ៉ា៖

«ម្នាក់នោះមានចំណុចសង្ស័យច្រើន! នៅមិននៅ ទៅជួបគេធ្វើអី!?»

Rose ក្រពាត់ដៃ ពេបមាត់ សម្លឹងបុរសម្ចាស់សំណួរនេះ ចុះឡើងពីក្បាលដល់ចុងជើង គឺនាងមានចេតនាបង្ហាញជាចំហថា នាងជិនឆ្អន់គេ៖

«សង្ស័យ? អាហ្នឹងវាជាការងាររបស់ពួកលេខា Professional ដែលម៉ៃ្ញៗគិតសង្ស័យ ម៉ូយដុំរបស់ចៅហ្វាយ ឬមួយនេះជាការងារចោលម្សៀតរបស់ពួកលេខាម៉ារៀលៗ ដែលអត់អីធ្វើ សន្សំអាក្រេឌីតអស់នេះយកចិត្តតោងតំណែង?»

«Rose ពាក្យនេះជាពាក្យ មើលងាយគ្នា!»

«គេនេះសក្តិសមនឹងទទួលបានច្រើនជាងហ្នឹងទៀត!»

នាងក្រពាត់ដៃថាឱ្យទាំងញញឹម ព្រោះពេលមហាវីនឃាត់ Roseយល់ថា គេឃាត់នាងព្រោះតែការដៀលថាលេខាស្មើនឹងដៀមដាមឲ្យដល់ម្ចាស់។ នាងដឹងដូច្នេះរឹតតែចង់បញ្ឈឺគេតទៅទៀត៖

«មហាវីនគិតថាសម្តីប៉ុណ្ណឹងជាការមើលងាយ ចុះដែលគេមកតាមដានខ្ញុំ វាអត់មើលងាយមើលថោកគ្នាទេ!?»

មហាវីននៅស្ងាត់ស្ងៀម។ នាងក្តាប់មាត់និយាយ៖

«ប្រើផ្តែបើមិនទុកចិត្តទេ បណ្តេញចេញទៅ!»

នាងដាក់កាតមកលើតុ ហើយបែរទៅរកទ្វារ។ មហាវីនជ្រួញថ្ងាស ញីចិញ្ចើមស្មុគចិត្ត។ គេហៅនាងឃាត់ដំណើរ៖

«Rose!»

ពិធីការឈប់ តែនាងមិនបែរមកទេ នាងនិយាយបន្ថែម៖

«Lorenzo ក៏ខ្ញុំកំពុងតាមដានដែរ ខ្ញុំចង់ដឹងដូចគ្នា គេនៅពីក្រោយរឿងបាត់ខ្លួនភ្ញៀវយើងដែរអត់!? តែឥឡូវនេះ ខ្ញុំជួយអីមិនបានទៀតទេពេលនេះ ព្រោះមហាវីន យកពួកមនុស្សអត់បានការ ពួកជំនាញចេះចាក់ចុចអត់ប្រយោជន៍មកនៅក្បែរខ្លួន! យើងដើរផ្លូវផ្សេងគ្នាវិញទៅ ក្រែងនៅអាចល្អទៅថ្ងៃក្រោយ!»

មហាវីនរវើ្នកគិតចុះឡើង។ អ្នកមានម្នាក់នេះដឹងថា ការបាត់បង់ Rose ទៅជារឿងគួរឲ្យខាតបង់។ គេធ្វើសញ្ញាដាក់ដេវីដ ធ្វើឲ្យលេខាបង្ខំចិត្តចាកចេញទៅទាំងមិនអស់ចិត្ត។

«សុំទោស Rose!»

សម្ដីគេខ្លីតែធ្វើឲ្យ នាងញញឹមបានចិត្ត។

ពេលស្រីស្អាតកាន់តែលេងឫកខ្លាំង មហាវីនកាន់តែនិយាយបន្ថែម៖

«មួយរយៈនេះ ឃើញហើយខ្ញុំក្រពុលមុខណាស់! នៅមិននៅ នាងបិទកូនប៉ូលិសនោះ មិនឲ្យចូលរួមសមោសរពណ៌ព្រះចន្ទ ហើយឧស្សាហ៍ចេញចូលជួបអាអាណិកជននោះ រឿងអីខ្ញុំមិនសង្ស័យ?»

Rose បែរមកវិញ ហើយនិយាយ៖

«ខ្ញុំមិនត្រឹមតែបិទក្មេងស្រីនោះមិនឲ្យមកទេ ខ្ញុំចង់បិទកម្មវិធីនេះបណ្ដោះអាសន្នទៀត!»

«ហេតុអី?»

ការបិទសមោសរដ៏គួរឲ្យត្រេកត្រអាលនេះ ជារឿងដែល Rose ដឹងហើយថា មហាវីនគ្មានថ្ងៃធ្វើទេ តែកាលៈទេសៈនេះ នាងត្រូវតែនិយាយចេញនូវអ្វីដែលនាងបានគិត។ នាងនិយាយដោយសម្លឹងភ្នែកថៅកែ៖

«ខ្ញុំគិតដូចមហាវីន! អ្នកណាម្នាក់កំពុងធ្វើស្អីមួយដែលពិបាកនិងឲ្យនិយមន័យ ប៉ុន្តែអារម្មណ៍ខ្ញុំគឺ វាដូចជាកំពុងប្រើប្រាស់កម្មវិធីយើងដើម្បីចាត់ការរឿងអ្វីមួយផ្សេង ហើយយើងខ្លួនឯងដែលជាអ្នកខាតបង់!»

មហាវីនដកដង្ហើមធំ។

គេបែរទៅច្រត់ដៃលើតុធ្វើការសម្លឹងទៅទិដ្ឋភាពខាងក្រៅហើយនិយាយមួយៗ៖

«ចុះបើអ៊ីចឹងយើងបិទកម្មវិធីចោល គឺយើងឆាប់យល់ព្រមខាតបង់ពេកហើយ!»

«បណ្ដោះអាសន្នទេ! សមោសរនេះខ្ញុំស្រលាញ់ស្មើអនាគតរបស់ខ្ញុំ ខ្ញុំចង់ការពារវា បានជាខ្ញុំរកវិធី!»

គេងាកមកវិញពេលទទួលអារម្មណ៍ថា មុននេះខ្លួនពិតជាមានកំហុសដែលបានគិតខុសលើនាង។ បុរសជាត់និយាយត្រង់ៗទៅកាន់គូសន្ទនា៖

«អា Lorenzo ហ្នឹងហើយដែលគួរឲ្យសង្ស័យបំផុត! នៅសុខៗមកព្រមជា Sponsor Gold ចូលរួមកម្មវិធី កាលហ្នឹងបើខ្ញុំមិនស្ដាប់នាង ខ្ញុំក៏មិនកុងត្រាវាដែរ! ឥឡូវនេះមកចេញរឿងចម្លែកច្រើន ខ្ញុំចង់ដឹងថា វាមានបំណងស្អី? ស្រីៗគ្រប់គ្នាចេញទៅជាមួយវាក្រោយជប់លៀងហ្នឹងផងក៏មិនដឹង!»

នាងរវើ្មកគិត ហើយពេលនេះប្រធានបទសំខាន់បញ្ចាំងឡើងក្នុងគំនិតនាង គឺសម្ដីវិភាគរបស់មហាវីន ព្រមទាំងពីចរិតបុរសអាណិកជន Lorenzo រឿងពីរដែលនាងយកមកផ្ទួផ្គងគ្នា។

«Loren! លោកដឹងរឿងស្រីៗបាត់ខ្លួនអស់ទាំងហ្នឹងអត់?» «រឿងណាមិនទាក់ទងជាមួយខ្ញុំ ខ្ញុំមិនចង់ដឹងទេ!» ។

នឹកឃើញត្រង់នេះសម្ដីនិយាយគ្នាទាំងនេះ នាងរអ៊ូអុះៗម្នាក់ឯង៖

«មិនសមហេតុផលមែន! Lorenzo បានញ៉ាំបាយជជែកជាមួយស្រីៗអស់នោះ ចុះម៉េចគេឆ្លើយស្រួលៗ ថារឿងមិនទាក់ទងជាមួយគេ គេមិនចង់ដឹង? ហោចណាស់គេគួរតែអាណិតដែលពួកនាងនៅសុខៗ បាត់ខ្លួនទៅអស់?»

មេពិធីការទម្លាក់ភ្នែកចុះសម្លឹងឥដ្ឋពេលមហាវីន ងាកមកសម្លឹងនាង។

ស្រីស៊ីវិល័យនិយាយម៉ត់ចត់៖

«បើខ្ញុំជាអ្នកក្រៅ ឬជាប៉ូលិស ការសង្ស័យទៅលើ Lorenzo និង មហាវីន ជុំវិញការបាត់ខ្លួនស្រីៗ យ៉ាងចម្លែកនេះមានភាគរយស្មើគ្នា! »

គេសើចខឹកចំអកនាង។

«ល្អហើយ ដែលខ្ញុំជះលុយជាច្រើនជួលមនុស្សឱ្យមកឈរសង្ស័យចៅហ្វាយខ្លួនឯង!»

នាងតបតមិនព្រមអន់៖

«នេះខ្ញុំស្មានថាមហាវីនចង់ឮពាក្យពិត!»

គេបន្ទូរឥរិយាបថតាមរយៈការដង្ហើមវែង អត់ធន់នឹងសម្ដីនាង ហើយសង្កត់ចិត្តឆ្លើយ៖

«ដំណាក់កាលនេះយើងត្រូវនៅពីក្រោយគ្នា មិនមែនបន្ទុះបង្អាប់គ្នាទេ Rose!»

នាងបន្ធូរភាពតឹងតែងដូចគ្នាហើយនិយាយតបវិញ៖

«ទុករឿងLorenzoឲ្យខ្ញុំតាមដាន! ខ្ញុំក៏យល់ស្របថាគេមានចំណុចគួរឲ្យសង្ស័យ! តែមហាវីនត្រូវព្រមជាមួយខ្ញុំ!»

គេងក់ក្បាលផ្ងក់ៗ ពេលនាងងើបមុខសម្លឹងមកស្វែងរកការសម្រេចចិត្ត ឃើញដូច្នោះ Rose និយាយបន្ត៖

«យើងផ្អាកកម្មវិធី ចាំមើលប៉ះពាល់ប្រយោជន៍អ្នកណាខ្លះ ហើយឲ្យតែគេចេញសកម្មភាព យើងនឹងអាចសម្គាល់ដឹងភ្លាម!»

«ចុះបើប៉ូលិសសួរ!?»

មហាវីនដាក់សំណួរខ្លី ធ្វើឲ្យគូសន្ទនាក៏ស្មុគស្មាញតាមនាយ។

ពួកគេនៅស្ងៀមស្ងាត់ តែចិត្តនាងនឹកដល់សម្ដីបុរសអាណិកជនស្រស់សង្ហា «បើមិនមែនបានធ្វើអីខុស ចាំបាច់អីទៅកើតទុក្ខខ្វល់ថាអ្នកណាតាមដាន?»

Rose ដកដង្ហើមធំ នាងដើរចូលក្បែរមហាវីន ហើយចាប់ដៃនាយយ៉ាងណែន។

ពេលគេឱនសម្លឹងដៃស្រីស្អាតនិយាយបញ្ឆោក់ស្រាលៗ៖

«ដូចមហាវីននិយាយម្សិលមិញអ៊ីចឹង! បើយើងមិនបានធ្វើអីខុស ចាំបាច់អីទៅកើតទុក្ខខ្វល់ថាអ្នកណាតាមដាន! ប៉ូលិសគង់តែមក! បើចាំបាច់យើងសហការជាមួយគេទៅ! យើងរកស៊ីត្រឹម

ត្រូវ បង់ពន្ធ គេត្រូវការពារ Event របស់យើង! បើកម្មវិធីយើងមានបញ្ហាភារកិច្ចគេគឺរកមូលហេតុមកឱ្យយើង! ចាំបាច់អីយើងគេច!»

មហាវីនងក់ក្បាលយឺតៗសម្លឹងមុខនាង

វគ្គ កូនស្រីប៉ូលិស

ទីតៗ...

ឱត សាម៉ុន ទទួលការហៅរបស់ឯកមាន។

គាត់ងាកឲ្យសញ្ញាចិត្រាដែលកំពុងអង្គុយធ្វើការក្បែរកាយ... ខ្លួនឯងងើបទៅរុញទ្វារបិទ... ឆែកបង្អួច មុនពេលឱនមកចុចទទួលហើយនិយាយ...

«ទទួល!»

សំឡេងឯកមាន លាន់មកលឿនស្មេរះ

«អ្នកទាក់ទងមកអ្នកនាងផានូ ជាមនុស្សកាន់ប៉ាសស្ព័រមកពីប្រទេសអង់គ្លេស តែមានដើមកំណើតខ្មែរ! ឈ្មោះប្រើផ្លូវការ សួន វិធីតាហើយនៅក្រៅគេហៅថា បង Rose! មានប្រវត្តិជាអ្នករៀបចំកម្មវិធីធំៗនៅឡុងដុង ភាគច្រើនជាសមោសរបណ្ដាពួកអ្នកមានឬ Fashion Week! មកនៅភ្នំពេញបានជិតមួយឆ្នាំ ស្គាល់មហាវីនតាំងពីមកដល់ភ្លាម ហើយជួយការងារគេ! គាត់រស់នៅក្នុងវីឡាមួយ តម្លៃកន្លះលានដុល្លារ ជិះឡានស្ព័រតម្លៃ២០ម៉ឺន ចេញចូលហាងសាឡនញឹកញាប់ឲ្យធីបច្រើនៗ!»

ពេលដែលដៃចិត្រាកត់ត្រាយ៉ាងញាប់ ឱត សាម៉ុន សួរកាត់សេចក្ដីរាយការណ៍របស់ Hacker ៖

«ហើយអាសមោសរ ពណ៌ព្រះចន្ទហ្នឹង រកលុយបានមួយយប់ប៉ុន្មានលាន បានជាពិធីការសុទ្ធតែលំដាប់?»

គ្មានចម្លើយ។ គាត់និយាយបន្ថែមៈ

«អាចជាខែលរៀបចំការរកស៊ីលក់ភេទទេដឹង??»

«សុទ្ធតែកូនអ្នកមានទាំងអស់ទាន! ទំនងតែគ្មានរឿងដោះដូរអ៊ីចឹងទេ មានតែយល់ព្រមសងខាង!»

ចិត្រាបដិសេធបែបនេះ ប៉ុន្តែឯកមាន និយាយបញ្ច្រាសៈ

«ថាមិនច្បាស់ដែរ! អ្នកមានៗប៉ុន្តែអាចទ័លលុយចាយដែរ អ្នកណាធានា? កូនអ្នកមានច្រើនខ្វះអីដែលលេងល្បែងជ្រុលខ្លួន មិនហ៊ានសុំលុយម៉ែឪ លេងម៉ូតឡានបង្អួតសង្គម យើងម៉េចដឹង? ចំណែករឿងកុម្ម៉ង់ខោអាវក្នុងនោះវិញ រឹតតែរកបកស្រាយមិនចេញ! ទៅសមោសរសោះ ទិញគ្រឿងក្នុងថ្លៃៗទៅតាមធ្វើអីដែរ?»

ឱត សាម៉ុន និងស័ក្តិបួនចិត្រាងាកមើលមុខគ្នា។

បរិយាកាសស្ងាត់ ម្នាក់ៗដឹងថាការគិតល្អិតល្អន់ច្បាស់លាស់ ទើបជាដើមទុនធំជាងគេសម្រាប់ក្តីដ៏ស្មុគនេះ។

«ខ្ញុំមានរបស់ខ្លះបង្ហាញ ហើយខ្ញុំត្រូវទៅផ្ទះលោកនាយឥឡូវនេះ!»

ស័ក្តិបួន ឯកមាននិយាយបន្ថែម។

ចិត្រាដឹងថាមិត្តម្នាក់នេះកំពុងរកបានអ្វីម្យ៉ាង ដែលមិនចង់និយាយតាមរយៈបណ្តាញបញ្ជូនសំឡេងទេ។

«មកចុះ ឯកមាន!»

ឧត្តមសេនីយ៍ឆ្លើយហើយងើបមុខសម្លឹងទៅក្រៅបង្អួច។

លោកឃើញកូនស្រីតែមួយគត់ ឱបកុំព្យូទ័រចុះពីលើឡានហើយដើរយ៉ាងរហ័ស ស្លេវ ឆ្ពោះមកក្នុងផ្ទះ។ ចិត្រាឃើញភាពព្រួយបារម្ភ លេចឡើងក្នុងកែវភ្នែកបុរសម្នាក់នេះពេលគាត់តាមសម្លឹងឥរិយាបថរបស់កូនស្រី។

«អ្នកនាងអមរាជា គ្មានរឿងអីទេទាន ព្រោះគាត់មិនបានទទួលការអញ្ជើញ!»

ឱត សាម៉ុន ងក់ក្បាលតិចៗ តែគាត់និយាយផ្សេងពីកាយវិការៈ

«វាមានហេតុផលអីម្យ៉ាង ដែលមិនទទួលកូនខ្ញុំ ឬអាចថាកំពុងមានផែនការអ្វីមួយធ្វើមកលើកូនខ្ញុំជាសម្ងាត់ផងក៏ថាបាន! ធម្មតា ចាស់ថាទឹកនឹងច្រើនមានក្រពើ សភាពកាន់តែស្ងប់ខ្ញុំកាន់តែប្រយ័ត្ន!»

ចិត្រារិះគិតម្នាក់ឯង។ បើធៀបជីវិតយុវវ័យមិនដែលមានភារៈជាឪពុក គេពិតណាស់មិនយល់ដល់ឡើយថា ការព្រួយបារម្ភ របស់លោកប៉ាម្នាក់លើកូនស្រីក្មេងសេចក្តី ស្ថិតក្នុងកាលៈទេសៈបែបនេះទៀត អាចមានជ្រាលជ្រៅកម្រិតណា? ចំណែកនារីនេះ មិនត្រឹមតែមានឆ្នាំដូចអ្នកបាត់ខ្លួនមុនៗ ថែមទាំងបានដាក់ពាក្យទៅចូលរួមដែរ ហេតុអ្វីបានជានាងត្រូវគេបដិសេធ?

«បើវាត្រូវការនារីៗកើតឆ្នាំ ២០០០ ម៉េចក៏វាបដិសេធអ្នកនាង? ចុះចំណែកអ្នកនាងផានូ គាត់ឆ្នាំងរោងដែរអត់?»

គេនិយាយតាមចម្ងល់ចិត្ត ស្រាប់តែសំឡេងអមរាជា លាន់មកពីក្រៅ៖

«លោកប៉ា? លោកប៉ា!»

ស្នូរគោះទ្វារធ្វើឲ្យបុរសទាំងពីរដែលកំពុងនៅខាងក្នុងប្រែជាស្រលាំងកាំង។ អ្វីដែលពួកគេគិតឃើញក្នុងគ្រាប្រថុចញ៉ុចនេះគឺថា តើនាងមានរឿងសំខាន់អីទៅបានជារត់ឱបកុំព្យូទ័រ មករកឪពុកក្នុងបន្ទប់ធ្វើការ។

«ចូលមកកូន!»

កូនស្រីមេប៉ូលិសរុញទ្វារចូលមក ហើយនាងទាក់ទើរ ពេលឃើញវត្តមានចិត្រា។ យល់សភាពការណ៍ នាយស័ក្តិបួនប្រញាប់ក្រោកឱនលំទោន ហើយវាចាមុន៖

«ខ្ញុំចេញទៅចាំនៅខ្សួសក្នុងសួនវិញទាន!»

នាងមិនបានវាចាអ្វីហាមឃាត់ចិត្រា ហើយថែមទាំងចៀសផ្លូវឲ្យនាយចេញទៅ។ ភាពស្លេកស្លាំងលើផ្ទៃមុខស្រីស្អាតដិតជាប់ក្នុងកែវភ្នែកស័ក្តិបួនជាតិ ចិត្រា។ គេមិនដែលឃើញនាងរលះរលាំងដល់ថ្នាក់នេះទេ។ លោកឧត្តមសេនីយ៍ប្រញាប់ហៅកូនឲ្យអង្គុយ ហើយផ្តោតភ្នែកលើកុំព្យូទ័រក្នុងដៃនាង។

«មានការអីត្រហេបត្រហបម៉េះកូនដា?»

នាងខ្សឹបខ្សៀវពេលអង្គុយក្បែរឪពុកៈ

«ប៉ា! កូនឃើញប៉ុ Roy នេះ ដូចជាមិនស្រួលសោះប៉ា!»

គាត់ជ្រួញចិញ្ចើមពេលកូនស្រីនៅសុខៗរំឭកពីឈ្មោះគូដណ្ដឹង ហើយមើលទៅអាការៈរបស់នាងហាក់មិនពេញចិត្តជាខ្លាំង។

មិនរង់ចាំឲ្យឪពុកសួរទាន់ ស្រីស្អាតបើកកុំព្យូទ័របង្ហាញគាត់។ ឧត្ដមសេនីយ៍ចង់ដាច់ផ្លារពេលឃើញរូបភាពសិចស៊ីនៃស្រីៗជាច្រើនសន្លឹក បិទនៅលើជញ្ជាំង ហើយត្រូវបានថតផ្ដិតមក ច្បាស់ទៃងលើអេក្រង់ ប្រៀបបីដូចជាអ្នកណាម្នាក់បានផ្ញើវាមកឲ្យអមរាដា។

ឧត្ដមសេនីយ៍មើលមុខកូន។ ប្រសិនចង់ថានាងប្រចណ្ឌ ដូចជាមិនសមទេ ព្រោះថាស្រីៗទាំងនោះដូចជាគាត់ធ្លាប់បានស្គាល់នៅកន្លែងណាមួយ?

«អ្នកបាត់ខ្លួនទាំងបួននាក់?»

គាត់គិតឃើញហើយប្រហោងពោះ។

ជាមួយកែវភ្នែកព្រួយខ្វល់ស្រីស្អាតរបស់គាត់និយាយបន្ថែមៈ

«មិត្តភ័ក្ដិកូនគេឃើញក្នុងផ្ទះ Roy ថៃដន្យ គេក៏ថតមកឲ្យ! គេចង់បញ្ជាក់ថាម្នាក់ហ្នឹងមិនអាចផ្ញើអនាគតបាន តែខ្ញុំវិញយល់ផ្សេងណាលោកប៉ា! កូនយល់ថាបើគេនេះជាអ្នកនៅពីក្រោយរឿងចាប់ ស្រីៗ ប៉ូលិសរកយ៉ាងណា ក៏បំបែកក្ដីនេះមិនចេញដែរ!»

ស្នងការថ្លោះទឹកមុខ តែមាត់គាត់ខំពោលការពារៈ

«គេជាស្នងការ គេអាចបិទរូបអ្នករងគ្រោះទុកធ្វើការ មានអីចម្លែក!?»

«ហើយចុះម៉េចក៏បិទតែរូបសិចស៊ី លេចលើលេចក្រោម! គេមានរោគចិត្ត គេចូលចិត្តស្រីៗរបៀបអ៊ីចឹង!»

នាងនៅក្មេងមែន តែការវាយតម្លៃរបស់នាង ហាក់ល្អិតដូចប៉ូលិស។ បុរសចំណាស់លើកដៃអង្អែលក្បាលកូន។

«កុំស្មានអីស្រួលៗ ងាយៗពេក វាអយុត្តិធម៌សម្រាប់គេ!»

នាងបង្ហាញការព្រួយបារម្ភដ៏ជ្រាលជ្រៅតាមរយៈពន្លឺភ្នែក ហើយសារភាពត្រង់ៗប្រាប់ឪពុក៖

«ប៉ា កូនចង់ផ្ដាច់ពាក្យ! ដាច់ខាតកូនមិនរៀបការជាមួយម្នាក់ហ្នឹងទេ!»

បុរសចំណាស់មិនអាចសម្រេចចិត្តតាមសម្ដីកូនក្នុងរឿងដ៏ធំមួយដែលប៉ះពាល់ដល់កិត្តិយសគ្រួសារទាំងសងខាងនេះបានទេ តែក្រសែភ្នែកនាង គឺច្បាស់លាស់ណាស់ ថានាងចង់បានការយល់ចិត្តនិងគាំទ្រ។

គាត់លូកដៃម្ខាងក្រសោបកូនស្រី ធ្វើឲ្យនាងបិទកុំព្យូទ័រហើយនិយាយបន្ថែម៖

«ទោះគេមិនបានរោគចិត្តក៏កូនជាតិនេះមិនស្រលាញ់មនុស្សប្រុសធុនគេហ្នឹងដែរ! កូនមិនព្រមរៀបការជាមួយមនុស្សដែលខ្លួនឯងមិនស្រលាញ់ទេប៉ា!»

នេះជាចរិតទៀងត្រង់របស់នាង ហើយការនិយាយស្ដីបើកទូលាយ ហ៊ាននិយាយ ហ៊ានបដិសេធ ខុសពីការខ្លាចចិត្តឪពុកម្ដាយនៃបណ្ដាកូនអ្នកមានយសសក្តិមួយចំនួន ដែលក្រោយមកការរៀបការដោយចាប់ដាក់បានបំផ្លាញអនាគតរបស់ពួកគេ។

លោក ឌិត សាម៉ុន យល់ថានាងមានភាពស្និទ្ធស្នាលនឹងឪពុក ហើយអមរាដា កំពុងទ័លមិនមានអ្នកណាអាចជួយដោះស្រាយ។

គាត់អង្អែលសក់នាងហើយលួងលោម៖

«ប៉ាគាំទ្រ!»

នាងញញឹមឱបកលោក ដោយទម្លាក់កុំព្យូទ័រចោល។

«តែប៉ាសុំ! កុំធ្វើអ្វីគ្រាំគ្រេងតាមចិត្ត គេមានឋានៈ គ្រួសារទាំងសងខាង មើលមុខគ្នាលែងត្រង់បើយើងធ្វើមិនស្រួល! ទុកពេលឲ្យប៉ាបន្តិច! មួយទៀត fileនេះកុំឲ្យធ្លាយចេញទៅណាក្រៅ! ស្នងការRoy អាចត្រូវគេយល់ខុសលើ ហើយខូចមុខមាត់ប៉ូលិស!»

នាងងក់ក្បាលទទួលឱវាទនេះ។ ឆ្លៀតឱកាសបុរសជាឪពុកខ្សឹបប្រាប់បន្ត៖

«អមរាជា! មានរឿងសំខាន់មួយកូនគួរតែដឹង ព្រោះកូនធំហើយ! ប៉ាយល់ថាកូនចេះបែងចែក អ្វីត្រូវ អ្វីខុស អ្វីលេងសើច ហើយអ្វីទៅជារឿងសំខាន់!»

នាងធ្វើភ្នែកម៉ក់ៗសម្លឹងគាត់ គាត់និយាយបន្ថែម៖

«អ្នកបាត់ខ្លួនសុទ្ធតែកើតឆ្នាំដូចកូន ហើយមានអាយុ១៨ដូចគ្នា! ប៉ាកំពុងសង្ស័យពីភូតព្ភសាស្ត្រ អំពើងងឹត ឬអ្វីក៏ដោយឲ្យតែទាក់ទងជាមួយមនុស្សស្រីឆ្នាំរោង! ប៉ាគិតថា បើការសន្និដ្ឋាននេះត្រឹមត្រូវ កូននៅក្នុងចំណុចស៊ីបហើយ វានៅឯណា យើងក៏មិនដឹង តែចុងព្រួញវាសំដៅមក! កូនត្រូវប្រយ័ត្នខ្លួនជានិច្ច ប្រាប់ប៉ាជានិច្ចនូវបណ្ដារឿងរ៉ាវមិនធម្មតាណាមួយដែលកូនសង្ស័យ!»

ភាគទី១៤

នារីនេះកាន់តែស្លេកស្លាំងពេលបាន ឮពាក្យពិតដែលឪពុកដាច់ចិត្តបង្ហើបក្នុងពេលនេះ។

នាងរុញម្រាមដៃបញ្ចូលគ្នា ហើយប្រឹងទប់ស្កាត់នូវការព្រួយខ្វល់ខ្វាយ។

កាយវិការនាង មិនអាចលាក់កំបាំងពីលោកនាយម្នាក់នេះឡើយ ម្ល៉ោះហើយគាត់លួងលោមបន្ថែម៖

«ប៉ាមិនឲ្យវានោះបានសម្រេចទេ! មិនយូរមិនឆាប់ ប៉ានឹងវែកមុខវា!»

«ចុះកូន? កូនត្រូវធ្វើម៉េចខ្លះទៅ?»

ឧត្តមសេនីយ៍ទម្លាក់ដៃពីសក់ក្បាលមកអង្អែលខ្នងស្រាល លុបបំបាត់ភាពខ្វល់ភ័យចេញពីចិត្តនាង។ គាត់ស្រដីថ្នមៗ៖

«ប៉ាដឹងថាអ្នកដែលបាត់ខ្លួនទាំងអស់ មិនមែនជាគម្រោងការមួយកើតភ្លាមធ្វើភ្លាមទេ! មនុស្សអាក្រក់អស់នោះទំនងជារៀបចំកិច្ចកលមកជាយូរ បើមិនអ៊ីចឹងកូនស្រីអ្នកមាន មានបរិវារឆ្វេងស្ដាំអស់នោះម៉េចនឹងងាយធ្លាក់ក្នុងកណ្ដាប់ដៃវា?»

ឈប់ត្រង់ណេះក៏ឃើញនាងសម្លឹងគាត់ដោយកែវភ្នែកគ្រលួងៗ ឪពុកក៏និយាយចូលដល់ចំណុចសំខាន់៖

«ប៉ាសុំសិទ្ធិតាមដានទូរស័ព្ទដៃ Fecebook Instagram laptop គ្រប់យ៉ាងដែលពួកវាអាច Hack ចូលបាន យើងអាចនឹងរកឃើញដាន!»

នាងងក់ក្បាលភ្លាម ដោយមិនបង្អង់ បង្ហាញថាកូនស្រីប៉ូលិសជាមនុស្សយល់ការណ៍ ជាងដែលគាត់ធ្លាប់គិត។ ឱិត សាម៉ុន អង្អែលក្បាលនាងហើយបន្ថែម៖

«តែសកម្មភាពតាមបណ្ដាញទាំងនោះធ្វើដូចធម្មតា កុំឲ្យគេចាប់ថ្នាក់បាន!»

«កូនយល់ហើយ!»

«រឿងនេះហាមឲ្យអ្នកណាដឹង! អ្នកម៉ាក់ក៏ដោយ!»

«ចាំ!... ប៉ុន្តែចុះអង្គរក្សពីរនាក់នោះ?»